ក្នុងកំឡុងជីវិតដ៏ខ្លីរបស់អ្នកខាងមុខនេះ ។ ហើយសំខាន់បំផុត គឺអ្នកយកបណ្ដាំអញនេះទៅផ្សាយប្រាប់គ្នាយើងជំនាន់ក្រោយ ៗ ដើម្បីឱ្យប្អូន ៗ យើងបន្តការតស៊ូរបស់យើងនេះរហូតដល់បានជ័យជំនះ ។

ម៉្យាងទៀត ត្រូវអ្នកកុំរុញរានឹងសេចក្ដីសម្រេចចិត្តនេះ។ មិនត្រូវឱ្យនរណាមកប្រឆាំងនឹងគំនិតនេះបានឡើយ ។ ចូរពួកឯងកុំស្ដាប់ពាក្យដែលគេឃោសនាថា មនុស្សនិងសត្វមានសេចក្ដីត្រូវការដូចគ្នា ឬ ថាសេចក្ដីចម្រើនរបស់មនុស្ស គឺជាសេចក្ដីចំរើនរបស់សត្វនោះ ។ មនុស្សមិនដែលបម្រើប្រយោជន៍នរណា ក្រៅពីប្រយោជន៍វាទេ ។ ដូច្នេះ គួរយើងទាំងអស់គ្នា រួមគ្នាជាធ្លុងមួយចិត្តមួយក្នុងការតស៊ូនេះ ។

មនុស្សទាំងអស់ជាសត្រូវ ! សត្វទាំងអស់ជាមិត្ត !

និយាយមកដល់កន្លែងនេះ ស្រាប់តែមានសម្លេងផ្អើលឆោឡោឡើង ។ មានកណ្ដុរធំបួនល្បូនចេញពីរូងវាហើយមកអង្គុយស្ដាប់ ។ ឆ្កែឃើញភ្លាមដេញភ្លែតកណ្ដុររត់ប្រាសយកអាយុ ចូលរូងវិញយ៉ាងប្រញាប់ ។ អា "គំនិត" ឃើញដូច្នោះហើយ ក៏លើកដៃដើម្បីសូមសេចក្ដីស្ងាត់ ។ វាបន្តទៅទៀតថា: "សមមិត្ត ! នេះជារឿងមួយដែលត្រូវតែដោះស្រាយភ្លាម ។ ចំពោះសត្វព្រៃដូចជាកណ្ដុរឬទន្សាយ តើ



វាជាមិត្តឬជាសត្រូវរបស់យើង ? យើងត្រូវតែសម្រេចដោយវិធីបោះឆ្នោត ។ អញសូមដាក់បញ្ហានេះឱ្យអង្គប្រជុំពិនិត្យ : "តើ កណ្ដុរជាមិត្តយើងឬទេ?"

ការបោះឆ្នោតក៏ប្រព្រឹត្តឡើងភ្លាម ។ មតិភាគច្រើនបានយល់ថាកណ្ដុរជាមិត្ត ។ មានតែសម្លេងបួនទេ ដែលប្រឆាំង គឺអាឆ្កែបីនិងឆ្មា ។ ក៏ប៉ុន្តែក្រោយមក អាបួននាក់នេះ បានស្របមតិតាមគេវិញទៅវិញ ។

អាគំនិតបន្តទៅទៀតថា :

"អញដូចជាអស់អ្វីនិយាយទៀតហើយ ។ អញគ្រាន់តែចង់បញ្ជាក់ហើយរំលឹកថា យើងទាំងអស់គ្នា ត្រូវតាមព្យាបាទ មនុស្សនិងអំពើរបស់វា ។ អ្វីៗ ដែលមានជើងពីរ ត្រូវចាត់ទុកជាសត្រូវ ។ អ្វីៗ ដែលមានជើងបួនឬស្លាបត្រូវ ចាត់ទុកជាមិត្ត ។ ហើយត្រូវចាំឱ្យច្បាស់ថា ក្នុងការតស៊ូយើងនេះ យើងមិនត្រូវយកតម្រាប់តាមមនុស្សឡើយ ហើយដល់ពេលយើងឈ្នះវា យើងក៏មិនត្រូវប្រព្រឹត្តតាមអំពើអាក្រក់របស់វាដែរ ។ គ្មានសត្វណាត្រូវរស់ក្នុងផ្ទះ ដេកលើគ្រែ ស្លៀកខោអាវ ផឹកស្រា ជក់បារី កាន់លុយ ឬធ្វើជំនួញឡើយ ។ ទម្លាប់របស់មនុស្សជាអំពើបាប ។ ហើយសំខាន់បំផុត សត្វទាំងអស់មិនត្រូវជិះជាន់គ្នាឯងឡើយ ។ ទោះជាខ្សោយ

ប្ដេជ្ញាថា ភ្ជាប់ប្អូន យើងទាំងអស់ជាបងប្អូនគ្នា ។ ពិតត្រូវស្រឡាញ់គ្នាផង សព្វទាំងអស់ត្រូវស្មើគ្នា" ។

ឥឡូវ សមមិត្ត! អញនឹងប្រាប់អំពីយល់សប្ដិអញពីយប់មិញ តែអញមិនអាចរៀបរាប់ឱ្យបានល្អទេ ។ អញយល់សប្ដិឃើញលោកយើងនេះ ក្នុងពេលដែលគ្មានមនុស្សរស់នៅ វាធ្វើឱ្យអញនឹកឃើញរឿងមួយ ដែលអញភ្លេចបាត់ជាយូរអង្វែងហើយ ។ ជាច្រើនឆ្នាំមកហើយ កាលអញនៅពីតូច ម៉ែអញនិងស្ត្រីជាច្រើនទៀត តែងច្រៀងចម្រៀងចាស់មួយ ដែលអញនៅចាំបានតែបទភ្លេងហើយនិងពាក្យបីម៉ាត់ប៉ុណ្ណោះ ។ អញចេះអាបទហ្នឹងតាំងពីតូច តែឥឡូវអញភ្លេចអស់ហើយ ។ យប់មិញអញយល់សប្ដិឃើញចម្រៀងនោះ ។ ឥឡូវអញក៏ចាប់បានវិញនូវចំរៀងនោះបានទាំងអស់ ទាំងចំនុកទាំងបទ ។

អញនឹងច្រៀងឱ្យឯងទាំងអស់គ្នាស្ដាប់ ថ្វីបើអញចាស់ហើយ ហើយសម្លេងអញស្អកទៀតក៏ដោយ ។ ក៏ប៉ុន្តែដល់អញបង្រៀនឯងទាំងអស់គ្នាឱ្យចេះទៅ ឯងនឹងច្រៀងពីរោះជាងអញ ។ ចម្រៀងនោះមានឈ្មោះថា "បសិវត្តន៍" ។ និយាយចប់ហើយអាគំនិតគ្រហែមឱ្យធូរបំពង់កហើយក៏ចាប់ច្រៀង ។ ហើយដូចជាវាបានអះអាងពីមុនមែន សម្លេងវាស្អក តែវាច្រៀងបានល្អគ្រាន់បើដែរ ។



សត្វនៃស្រុកសប្រែង គវ៉ែ ៗ
សត្វនៅគ្រប់កន្លែង គវ៉ែ ៗ
ចូរស្ដាប់យើងថ្លែង ប្រាប់វែង ៗ
ពីរឿងនៅនាថ្ងៃមុខ ទៅមុខ ៗ
មិនយូរមិនឆាប់ឡើយណា ដោតតែយ ៗ
អាមនុស្សមុខជាក្ស័យ ប្រល័យ ៗ
យើងនៅស្រុកសប្រែង គវ៉ែ ៗ
មុខជាបានសប្បាយ គ្រប់កាយ ៗ
យើងនឹងរស់កន្ទុះ ពីប្រមុះ ៗ
រស់ពីខ្នង
ដំបងនឹងបាក់បែក
ដែកក៏នឹងច្រេះ រេះ ៗ
យើងនឹងសម្បូរ ហៀរហូរ ៗ
យើងនឹងសប្បាយ គ្រប់កាយ ៗ
ស្រូវ ពោត សណ្ដែក
ជាចំណែកយើងទាំងអស់ រំដោះ ៗ

ថ្ងៃនឹងរះរាល់ព្រឹក
ទឹកនឹងថ្លាគ្រប់អូរ
វាយោនឹងបក់បក់រំភើយ

នេះហើយហៅថាសេរី
យើងត្រូវតែពួតដៃ
ប្រយ័យបេះត្រាដល់ស្លាប់
ប្រញាប់ប្រញាល់ទាំងអស់
រំដោះយកសេរីភាព
សត្វនៃស្រុកសប្រេង    ពរ៉ែង ៗ
សត្វនៅគ្រប់កន្លែង    ពរ៉ែង ៗ
ចូរចាំស្តាប់យើងថ្លែង    ប្រាប់ឡែង ៗ
ពីរឿងនានាថ្ងៃមុខ    ទៅមុខ ៗ ”

ចម្រៀងនេះធ្វើឲ្យសត្វទាំងអស់សប្បាយស្រើបស្រាលយ៉ាងខ្លាំង ។ លុះអាគំនិតច្រៀងចប់ សត្វទាំងអស់ក៏នាំគ្នាច្រៀងតាម ។ អាល្ងង់ជាងគេក៏អាចចាំទំនុកនឹងបទបានខ្លះដែរ ។ ចំណែកអាគ្មាតដូចជាប្រផ្លុកនិងក្អែកអាចច្រៀងបានទាំងអស់ក្នុងរយៈពេលដ៏ខ្លី ។ ហើយក្រោយពីបានសាកល្បងចុះឡើងពីរបីដង  សត្វទាំងអស់ក៏ស្រែកច្រៀងចម្រៀងនេះព្រម ៗ គ្នា ។ គោរោទ៍ ឆ្កែលូ ពពែយំ សេះស្រែក ទាបន្លឺ ។ វាទាំងអស់សប្បាយនឹងចម្រៀង  វានាំគ្នាច្រៀងប្រាំដងបន្តបន្ទាប់គ្នា ។ វាប្រហែលជាច្រៀងរាល់ព្រឹកហើយមើលទៅ បើសិនជាគ្មានរឿងរំខានទេនោះ ។



ជាអកុសល សម្លេងនេះឲ្យគេដាស់ពូស៊ិត ដែលគាត់ក្រញាងចេញពីគ្រែ ក៏ស្មានថាមានឆ្កែចចកចូលក្នុងក្រោលសត្វ ។ គាត់កញ្ឆក់បានកាំភ្លើង ឈររបរកៀនបន្ទប់ហើយក៏បាញ់ប្រាំមួយគ្រាប់ ៗ គ្រាប់ចូលទៅក្នុងផ្ទៃងងឹត ។ គ្រាប់ទាំងអស់ចូលកប់ក្នុងជញ្ជាំងជង្រុក  ធ្វើឲ្យសន្និសីទរបស់សត្វទាំងឡាយត្រូវបញ្ចប់ភ្លាម ។ ម្នាក់ ៗ រត់ទៅកាន់ទីកន្លែងខ្លួនវិញ ។ សត្វស្លាបហើរទៅទំលើបង្គង សត្វឯទៀតក៏ដេកស្របថ្ពាបលើគំនរចំបើង ។  ហើយភូមិសប្រេងក៏ចូលកាន់សភាពស្ងប់ស្ងៀមជាថ្មីវិញ ។

# ជំពូក ២

បីថ្ងៃក្រោយមក អាគំនិតបានដេកស្លាប់យ៉ាងស្ងប់ស្ងាត់។ គេយកខ្មោចវាទៅកប់ចោលនៅឯចំការ ។

ហេតុការណ៍នេះបានកើតឡើងនៅដើមខែមីនា ។ នៅក្នុងកំឡុងបីខែបន្ទាប់ពីហេតុការណ៍នេះមក មានរឿងសម្ងាត់មួយបានកើតឡើង ។ សាររបស់អាគំនិតបានធ្វើឲ្យសត្វដែលចេះគិត មានសេចក្តី[illegible]ៀមជាថ្មីឡើងវិញក្នុងជីវិត ។ វាមិនដឹងថា បដិវត្តន៍ដែលអាគំនិតបានទាយទុកនោះនឹងផ្ទុះឡើង នៅពេលណាទេ ។ វាមិនជឿសោះថាព្រឹត្តិការណ៍នោះនឹងកើតមាននៅក្នុងពេលដែលវានៅរស់នៅឡើយក៏ទេដែរ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏វាត្រូវតែរៀបចំខ្លួនប្រាណឲ្យហើយ ។ ការហ្វឹកហ្វឺននិងការរៀបចំគំរោងការណ៍ ត្រូវធ្លាក់មកលើដៃពពួកជ្រូក ដែលគេយល់ថាជាអ្នកឆ្លាតនិងវាងវៃជាងគេទាំងអស់ក្នុងបណ្តាសត្វទាំងឡាយ ។ ក្នុងចំណោមអ្នកដែលលេចមុខជាងគេ គឺអា "សំឡី" និងអា "ឈ្មុះ" ដែលជាជ្រូកមានវ័យក្មេងហើយដែលពូស្វិតចិញ្ចឹមសំរាប់លក់ ។ អា "ឈ្មុះ" មានរាងធំដំបង តែកាច ជាជ្រូកពូជអង់គ្លេសតែមួយ



របស់ពូស្វិត ។ វាមិនសូវចេះនិយាយទេ តែចេះដោះស្រាយបញ្ហាដោយខ្លួនឯង ។ អា "សំឡី" រឿសរវៃជាងអាឈ្មុះ ចេះនិយាយពីរោះហើយមានគំនិតច្រើន គឺវាមានអាកប្បកិរិយាខុសពីអាឈ្មុះ។ ក្នុងចំណោមជ្រូកដទៃទៀតដែលពូស្វិតចិញ្ចឹមទុកយកសាច់ មានអាមួយនោះឈ្មោះអា "ប្រាជ្ញ" ។ វាមានរាងតូចតែធាត់ ថ្ពាល់ធ្លាក់សំយាក ភ្នែកមុត រហ័សរហួនហើយមានសម្លេងស្រួយ ។ វានិយាយពូកែ ។ ពេលវាជជែកដល់ចំណុចពិបាកម្តងៗ វាតែងតែមានមធ្យោបាយនិយាយបន្ទប់ពីនេះពីនោះ ហើយគ្រវីគ្រវាត់កន្ទុយដើម្បីបំភ័ន្តមតិឲ្យគេឆាប់ជឿ ។ អ្នកណាក៏ទទួលស្គាល់ថា អាប្រាជ្ញចេះធ្វើអ្វីៗ ដែលខ្មៅឲ្យទៅជាសបាន ។

ជ្រូកទាំងបីនេះបានរៀបចំពាក្យបណ្តាំរបស់អាគំនិត ឲ្យទៅជាគោលគំនិតធំៗ ដែលវានាំគ្នាដាក់ឈ្មោះថា "លទ្ធិសត្វនិយម" ។ ស្ទើរតែរាល់យប់ រាល់អាទិត្យ ឲ្យតែពូស្វិតចូលដេក វានាំគ្នាប្រជុំសម្ងាត់នៅក្នុងជង្រុកហើយពន្យល់អំពីគោលការណ៍នៃ "លទ្ធិសត្វនិយម" ដល់សត្វទាំងឡាយ ។ ថ្ងៃដំបូងមានការភ្ញាក់ផ្អើលនិងព្រងើយកន្តើយបន្តិច ព្រោះសត្វខ្លះនៅជាប់ចិត្តនិងមានភក្តីភាពចំពោះអាគំនិត ដែលវាបានចាត់ទុកថាជាព្រះគ្រូទៅហើយ ។ រីសត្វខ្លះទៀតនៅតែពោល

ដដែលៗថា: "ចៅហ្វាយស្មិតបានចិញ្ចឹមយើង ។ បើគ្មានគាត់ទេនោះ យើងមុខជាអត់បាយស្លាប់" ។ សត្វខ្លះទៀតឆ្លើយថា: "ចាំខ្វល់ធ្វើអ្វីទៀត ក្រោយពីយើងបានស្លាប់ទៅហើយ?" ខ្លះទៀតគិតថា: "បើបដិវត្តន៍នឹងផ្ទុះបែក តើវាខុសគ្នាត្រង់ណា បើយើងជួយក៏ដូចជាមិនជួយ ?" ។

សំណួរទាំងនេះ ធ្វើឱ្យជ្រូកពិបាកនឹងពន្យល់ថាជាគំនិតប្រឆាំងនឹងគោលការណ៍នៃលទ្ធិសត្វនិយមណាស់ ។ សំណួរដែលគួរឱ្យអស់សំណើចជាងគេគឺចេញមកពីមាត់ "មីប្រផេះ" មេសេះស ដែលសួរជាដំបូងទៅកាន់អាសំឡីថា: តើយើងនៅមានស្ករស៊ីទេ ក្រោយពីបដិវត្តន៍ ? ។

" អត់ទេ " អាសំឡីឆ្លើយដោយម៉ឺងម៉ាត់ទៅវិញភ្លាម ។ " យើងគ្មានមធ្យោបាយនឹងធ្វើស្ករទេក្នុងភូមិនេះ ហើយយើងក៏មិនត្រូវការស្ករទៀតដែរ ។ យើងនឹងស៊ីស្រូវ ដែលមានតាមចិត្តយើងចង់ " ។

" ចុះអញ អាចនៅពាក់បូនៅកអញបានទៀតទេ ? មីប្រផេះសួរតទៅទៀត ។

" មីសម្លាញ់ – អាសំឡីស្រែកឡើង អាបូដែលអ្នកស្រឡាញ់នោះវាជាសញ្ញានៃទាសភាព ។ តើអ្នកដឹងទេថាសេរីភាពវាមានតម្លៃជាងអាបូរបស់អ្នកនោះ ! " ។



មីប្រផេះស្របតាម តែហាក់ដូចជាមិនទាន់យល់ច្បាស់ ។

ជ្រូកមានការៈ កាន់តែលំបាកឡើងៗ ក្នុងការតស៊ូនេះ ព្រោះវាត្រូវប្រឆាំងនឹងពាក្យឃោសនាបំភ័ន្តរបស់អា " ខ្វក " ដែលជាក្អែកសាំងហើយជាសំណព្វតែមួយរបស់ពូស្មិត ។ អាខ្វកជាអ្នកយកការណ៍ ។ វាដឹងឮការសម្ងាត់ទាំងអស់ហើយវាជាអ្នកពូកែនិយាយផង ។ វាប្រកាសថា វាបានស្គាល់កន្លែងអាថ៌កំបាំងមួយហៅថា " ភ្នំស្ករៈ " ។ ភ្នំនេះជាទីដែលសត្វទាំងអស់ត្រូវចាប់កំណើតឡើងជាថ្មី ក្រោយពីបានចាកឋានពីលោកនេះទៅ ។ វាថាកន្លែងនោះនៅលើមេឃហួសពពកបន្តិច ។ នៅលើភ្នំស្ករៈ សត្វឥតធ្វើការអ្វីទេ រាល់អាទិត្យ ។ ស្ករ ផ្លែឈើ និងនំ មានគ្រប់រដូវ ។ សត្វទាំងអស់ស្អប់អាខ្វក ព្រោះតែវានិយាយរឿងចម្លែកៗ ហើយខ្ជិលធ្វើការ ។ តែសត្វខ្លះមានជំនឿលើភ្នំស្ករៈ ។ ជ្រូកមានការពិបាកច្រើនក្នុងការពន្យល់កុំឱ្យសត្វឯទៀតជឿទៅលើកន្លែងអាថ៌កំបាំងនោះ ។

អ្នកដែលមានចិត្តស្មោះស្ម័គ្រជាងគេ គឺអាព្រួញនិងមីកណ្ដូបសេះ ។ វាទាំងពីរនេះ មិនសូវចេះគិតទេ ។ ម្ល៉ោះហើយ ក្រោយពីពេលដែលបានទទួលយកជ្រូកជាមេដឹកនាំ វាជឿទាំងអស់នូវសំដីដែលជ្រូកនិយាយទាំងប៉ុន្មាន ហើយ

វាក៏និយាយប្រាប់បន្តទៅសត្វដទៃទៀត ។ វាមករួមប្រជុំសម្ងាត់ក្នុងជង្រុកជានិច្ចហើយច្រៀងយ៉ាងស្ងាត់ នូវចម្រៀង "បដិវត្តន៍" ក្រោយពេលបិទសម័យប្រជុំម្តងៗ ។

គិតទៅ បដិវត្តន៍ ហាក់ដូចជានឹងកើតមានក្នុងពេលឆាប់ៗ ហើយហាក់ដូចជារៀបចំ បានស្រួលឡើងបន្តិចម្តងៗ ខុសពីការស្មានពីពេលមុន ។ ពីឆ្នាំមុន ពូស្មិត ដែលមានចិត្តសាហាវទៅលើពពួកសត្វ បានខិតខំធ្វើការជាប្រក្រតី ។ តែពេលថ្មីៗនេះ គាត់ហាក់ដូចជារាយមាយក្នុងកិច្ចការច្រើន ។ គាត់កើតទុក្ខទោមនស្សក្នុងចិត្ត ក្រោយពីបានខាតបង់ លុយកាក់ជាច្រើនដោយចាញ់ក្តីក្តាំ ហើយចាប់ផ្តើមផឹកស្រាកាន់តែច្រើនឡើងៗ ខុសធម្មតា ។ ជួនកាលគាត់ដេកលើកៅអីយោលរបស់គាត់នៅផ្ទះបាយ ពេញមួយថ្ងៃ មើលសាស្ត្រាបណ្ដើរ ផឹកស្រាបណ្ដើរ ។ ពេលនោះគាត់តែងតែកាច់ចំណិតនំជ្រលក់ក្នុងស្រារួចបោះឲ្យអាខ្វកស៊ី ។ គូលីនិងជើងឈ្នួលនៅទំនេរគ្មានការធ្វើ ហើយចេះតែឆ្មៀតបោកប្រាសគាត់ជានិច្ច ។ ស្មៅផ្ទុះពេញចំការ ដំបូលផ្ទះធ្លុះធ្លាយ របងបាក់បែក សត្វទាំងឡាយស៊ីមិនឆ្អែត ។

ខែមិថុនាមកដល់ ស្មៅត្រូវតែច្រូតទុក ។ ល្ងាចមិញជាល្ងាចថ្ងៃសៅរ៍ ។ ពូស្មិត ចេញទៅផ្សារ ហើយផាក់ស្រា



ហួសកម្រិត ។ គេទើបនឹងឃើញគាត់ត្រឡប់មកផ្ទះវិញ នៅរសៀលថ្ងៃអាទិត្យនេះ ។ ជើងឈ្នួលបានរឹតទឹកដោះគោទុកពីព្រឹករួចហើយក៏នាំគ្នាទៅបាញ់ទន្សាយអស់ ឥតរវីរវល់នឹងឲ្យចំណីសត្វទេ ។ ដល់គាត់ត្រឡប់មកដល់ផ្ទះវិញ ពូស្មិតក៏ប្រាស់ខ្លួនដេកលើគ្រែ យកក្រមាគ្របមុខលក់រហូតដល់ព្រលប់ ។ ម្ល៉ោះហើយសត្វទាំងអស់អត់ចំណីរហូត ថ្ងៃនោះ ។ មើលទៅវាទ្រាំទៅទៀតមិនបានទេ ។ គោមួយនោះដោយឃ្លានពេក ក៏ដើរតម្រង់ទៅជង្រុកដែលទុកចំបើង យកស្នែងវាទាំងពីរបុកបំបាក់ទ្វារ ។ សត្វទាំងឡាយក៏នាំគ្នាប្រញាប់ចូលទៅជាមួយ ។ ក្នុងពេលនោះ ពូស្មិតភ្ញាក់ឡើងហើយរត់ទៅកន្លែងដែលកើតហេតុ គាត់និងជើងឈ្នួលបួននាក់ទៀតក៏ចាប់វាយវាត់សត្វទាំងឡាយ ដោយរំពាត់យ៉ាងអស់ទំហឹងដៃ ។ អំពើនេះធ្វើឲ្យសត្វដែលកំពុងតែស្រេកឃ្លានអត់ទ្រាំតទៅទៀតមិនបាន ។ វាហាក់ដូចជាស្រុះគ្នាតែម្តងថ្វីបើពុំបានរៀបចំទុកជាមុនក៏ដោយ គឺសត្វទាំងអស់បានងាកមកតដៃវិញយ៉ាងស្វាហាប់ ។ ពូស្មិតនិងគ្នីគ្នាគាត់ត្រូវគោវាត់និងធាក់ស្ទើរគ្រប់ជ្រុង ។ ស្ថានការណ៍ហាក់ដូចជាកែលែងកើត ។ គាត់មិនដែលឃើញសត្វធ្វើយ៉ាងនេះសោះ ពីមុនៗមក ។ ម្ល៉ោះហើយ សត្វដែលគាត់ធ្លាប់តែវាយដំនិងធ្វើបាបតាមចិត្ត

បានធ្វើឱ្យគាត់និងគ្នីគ្នាភិតភ័យស្ទើរលោះព្រលឹង ។ ពូស្មិតនិងគ្នីគ្នាគាត់ក៏ដាច់ចិត្តរត់ចេញពីកន្លែងនោះ ។ ក៏ប៉ុន្តែនៅពេលដែលអ្នកទាំងនោះឡើងលើរទេះហើយ សត្វទាំងឡាយក៏ព្រួតដៃគ្នា រុញរទេះយ៉ាងលឿន ចេញមកក្រៅផ្លាក់រហូតទៅកណ្ដាលផ្លូវធំ ។

ប្រពន្ធពូស្មិត អើតក្បាល មើលតាមបង្អួច ឃើញហេតុការណ៍ដែលបានកើតឡើងទាំងអស់។ គាត់ប្រញាប់ប្រញាល់ប្រមូលអីវ៉ាន់ខ្លះដាក់ក្នុងស្បោង ហើយរកច្រកចេញរត់តាមផ្លូវផ្សេង ។ អាខ្វែកចេញពីរង្គុងហើយទទះស្លាបហើរតាមក្រោយស្រែកខ្វែកៗលាន់រំពង ។ ក្រោយពីបានដេញពូស្មិតនិងគ្នីគ្នាគាត់ចេញទៅដល់ថ្នល់ធំហើយ សត្វទាំងឡាយក៏នាំគ្នាបិទទ្វាររបងយ៉ាងប្រញាប់ ។

មុននឹងវាដឹងអំពីហេតុទាំងអស់ដែលបានប្រព្រឹត្តទៅអម្បាញ់មិញនេះ បដិវត្តន៍បានសម្រេចដូចបំណងហើយ ៖ ពូស្មិតត្រូវបណ្ដេញឱ្យចេញក្រៅ ហើយភូមិទាំងមូលត្រូវនៅក្នុងកណ្ដាប់ដៃសត្វទាំងអស់ ។

ដើមឡើយ សត្វទាំងអស់ហាក់ដូចជាមិនទាន់ជឿលើវាសនារបស់ខ្លួនទេ ។ វានាំគ្នារត់ជុំវិញរបង ខ្លាចក្រែងមានមនុស្សនៅបង្កប់ខ្លួនកន្លែងណាមួយ ។ រួចហើយទើបត្រឡប់



មកផ្ទះ ដើម្បីបំផ្លាញឱ្យអស់នូវសំណល់នៃអំណាចផ្ដាច់ការរបស់ពូស្មិត ។ បន្ទប់ដែលគេទុកប្រដាប់ប្រដាត្រូវបិទទ្វារចោល ។

ប្រឡោក ខ្សែ កន្ទុះ កាំបិតដ៏កំណាច ដែលពូស្មិតប្រើសំរាប់ក្រៀវជ្រូកនិងចៀមត្រូវបានប្រមូលយកទៅទម្លាក់ចោលក្នុងអណ្ដូង ។ បង្ហៀរសេះ ប្រឡោក របាំងភ្នែកស្បោងនិងអំពាត់ ត្រូវបានប្រមូលមកគរនៅកណ្ដាលទីធ្លាហើយដុតចោល ។ សត្វទាំងឡាយលោតកញ្ឆេងដោយសេចក្ដីរីករាយកាលបានឃើញរំពាត់ត្រូវភ្លើងឆេះ។ អាសំឡីយកបូដែលពូស្មិតតែងយកមកគុបតែងសេះនៅពេលទៅផ្សារម្ដងៗ នោះទៅបោះចោល ក្នុងគំនរភ្លើងរួចហើយវាពោលឡើងថា ៖ "បូត្រូវចាត់ទុកដូចជាសម្លៀកបំពាក់ដែលសំរាប់សំគាល់ភេទមនុស្ស ។ សត្វទាំងឡាយមិនត្រូវស្លៀកខោអាវទេ" ។

កាលបានឮដូច្នោះហើយ អាព្រួញក៏ចាប់កញ្ឆក់យកមួកចំបើងដែលវាតែងយកមកបិទត្រចៀកវាសម្រាប់ការពាររុយនៅពេលរដូវក្ដៅ បោះចូលទៅក្នុងគំនរភ្លើងនោះមួយរំពេច ។

ក្នុងវេលាដ៏ខ្លី សត្វទាំងឡាយបានបំផ្លាញអស់នូវវត្ថុដែលជាសំណល់របស់ពូស្មិត ។ អាឈ្មុះហៅប្រមូលសត្វ

ទាំងអស់ទៅជជ្រុំគហើយចែកពោតឲ្យពីរចំរែកគ្រប់ ៗ គ្នា។ ពួកវាក្តាបាននាំផុតពីរជុំម្នាក់ ។ វាទាំងអស់គ្នានាំគ្នាច្រៀងបទ "បដិវត្តន៍" តាំងពីដើមដល់ចប់ប្រាំពីរដងហើយក៏ទម្រេតខ្លួនសម្រាកលង់លក់យ៉ាងស្កប់ស្កល់ ។ វាពុំដែលស្គាល់សភាពបែបនេះម្តងណាសោះឡើយ ។

ព្រឹកឡើងវានាំគ្នាក្រោកពីព្រលឹមដូចសព្វដង។វានឹកឃើញអស់ហើយហេតុការណ៍ ដែលបានកើតកាលពីយប់មិញ ។ រួចវានាំគ្នាចេញទៅវាលស្មៅឯខាងក្រៅ ដែលនៅឯនាយបន្តិចនិងដែលមាន[ទួ]លខ្ពស់មួយ ។ កាលណាគេបានទៅដល់កំពូលទួលនោះ គេអាចមើលឃើញទិដ្ឋភាព[illegible] សម្រែងយ៉ាងជាក់ស្តែង ។ សត្វទាំងអស់រត់ស្រពេចគ្នាឡើងដល់កំពូលទួលនោះ ហើយខំសម្លឹងមើលចុះមកក្រោមជុំវិញខ្លួនឃើញទេសភាពភូមិនៅក្រោមពន្លឺថ្ងៃពេលព្រលឹម ។ ត្រូវហើយ ! នេះជាសម្បត្តិរបស់វា! អ្វីទាំងអស់ដែលវាបានឃើញ ជារបស់វា! វាលោតចុះលោតឡើង ចិត្តពោរពេញទៅដោយសេចក្តីរំភើប វាស្រែកទៅក្នុងអាកាសដោយសេចក្តីសម្រើបចិត្តយ៉ាងក្រៃលែង ។ វានៀលខ្លួនលើស្មៅដ៏ជោគដោយសន្សើម ។ វាបោចស្មៅទំពាពេញមាត់យ៉ាងឆ្ងាញ់ ។ វាឈូសបំបែកដីហើយ[illegible]ក្រមុះហិត ។



រួចហើយវាដើរមើលជុំវិញភូមិ ត្រួតពិនិត្យសព្វគ្រប់ដោយសេចក្តីរំភើបនិងសប្បាយ ។ វាមើលវាលស្រែ វាលស្មៅ ចំការ បឹង និងព្រៃគុម្ពោត ហាក់ដូចជាវាមិនដែលឃើញរបស់ទាំងនេះសោះ ។

រួចហើយវានាំគ្នាចូលភូមិវិញ ឈប់ស្ងៀមនៅមុខផ្ទះ។ ផ្ទះនេះក៏ជាសម្បត្តិរបស់វា ក៏ប៉ុន្តែវាហាក់ដូចជាខ្លាចមិនហ៊ានចូលទៅក្នុង ។ បន្តិចមកអាសំឡីនិងអាឈ្មុះយកស្មាដោលទ្វារទាល់តែរបើកហើយសត្វទាំងអស់ក៏នាំគ្នាចូលដោយតំរៀបគ្នាជាជួរមួយនិងដោយដាក់ជើងថ្នម ៗ ហាក់ដូចជាពុំចង់ឲ្យអ្វីៗកំរើក ។ វាដើរថ្នម ៗ ចូលពីបន្ទប់មួយទៅបន្ទប់មួយ ។ វាមើលដោយស្ងប់ស្ងៀមនិងដោយឥតចេញស្តីអ្វីមួយម៉ាត់ នូវគ្រឿងតែរតង នូវគ្រែដែលមានពូកច្រកសុទ្ធតែស្លាបសត្វ នូវកញ្ចក់ផ្លុះ កៅអី កម្រាល នូវរូបថត ដែលព្យួរនៅក្នុងបន្ទប់សំអាង ។ រួចហើយ វានាំគ្នាចុះមកក្រោ ។ តែរំពេចនោះគេដឹងថាបាត់មីប្រផេះ ។ គេក៏នាំគ្នាឡើងទៅវិញ ហើយក៏ឃើញមីប្រផេះនៅក្នុងបន្ទប់ដេក ។ វាកំពុងរើសបានបូពណ៌លឿងរបស់ប្រពន្ធពូស្មិត ហើយយកមកដាក់លើស្មាផ្ទុះផ្ទៀងផ្ទងមើលក្នុងកញ្ចក់ ។ ឃើញដូច្នោះ សត្វទាំងអស់ក៏ស្តីបន្ទោសមីប្រផេះ រួចហើយក៏នាំគ្នាដើរចេញទៅក្រៅ ។

សាច់ភ្លើរដែលព្យួរចោល ក្នុងផ្ទះបាយ ត្រូវបានយកទៅកប់ចោល ចំណែកឯធុងស្រាត្រូវអាព្រួញធាក់ចូលក្នុង ។ ក្រៅពីនេះ គ្មានរបស់អ្វីទៀតដែលត្រូវប៉ះពាល់ទេ ។ សត្វទាំងអស់បានសម្រេចចិត្តយកផ្ទះធ្វើជាសារមន្ទីរ ហើយហាមមិនឲ្យសត្វណាមួយរស់នៅកន្លែងនោះឡើយ ។

ក្រោយពីបានស៊ីឆ្អែតហើយ អាសំឡីនិងអាឈ្មុះក៏ចាប់កោះប្រជុំសត្វទាំងអស់ម្តងទៀត ។ " សមមិត្តទាំងអស់គ្នា !" អាសំឡីពោលឡើង " ឥឡូវម៉ោងទើបតែ៦កន្លះទេ យើងនៅសល់ពេលច្រើនណាស់ ។ ដូច្នេះចូរយើងនាំគ្នាច្រូតស្មៅ តែប៉ុន្តែអញមានរឿងមួយត្រូវដោះស្រាយជាបន្ទាន់សិន"។ ជ្រូកបានប្រាប់អង្គប្រជុំថា នៅក្នុងអំឡុងបីខែកន្លងមកនេះ វាបានខំហាត់រៀនខ្លួនឯងរហូតចេះអាននិងសរសេរ តាមសៀវភៅរៀនអានរបស់កូនពូស្មិតដែលបោះចោលក្នុងគំនរសំរាម ។ អាឈ្មុះប្រើឲ្យអាម្នាក់ដើររកកំប៉ុងថ្នាំពណ៌ខ្មៅនិងស ហើយក៏នាំគ្នាដើរទៅមុខទ្វាររបងផ្លូវធំ ។ នៅទីនោះអាសំឡីដែលពូកែសរសេរជាងគេទាំងអស់ ក៏ទាញជក់មកលុបឈ្មោះពូស្មិត ហើយសរសេរដាក់ឈ្មោះថ្មីវិញថា "វិមានសត្វ"។ ចាប់ពីឥឡូវទៅ កន្លែងនេះ នឹងមានឈ្មោះថា"វិមានសត្វ"។ បន្ទាប់មក ពួកវាក៏នាំគ្នាត្រឡប់មកក្នុងវិញ ។ អាសំឡីនិងអា



ឈ្មុះ បញ្ជាឲ្យរកជណ្តើរវែងមួយ ហើយឲ្យដាក់ផ្អែកទៅលើជញ្ជាំងជង្រុក ។ វាបានពន្យល់អង្គប្រជុំថា ក្រោយពីបានសិក្សាបីខែមក វាបានយកគោលការណ៍នៃលទ្ធិសត្វនិយមមកបំព្រួញបាននៅត្រឹមប្រាំពីរមាត្រា ។ មាត្រាទាំងនេះ ត្រូវចារទុកលើជញ្ជាំង ។ វានឹងទៅជាធម្មនុញ្ញមួយ ដែលឥតមាននរណាកែប្រែបាន សម្រាប់ឲ្យសត្វទាំងឡាយប្រតិបត្តិតាមតៗគ្នា ។ ដោយមានការពិបាកបន្តិច (ជ្រូកមិនអាចឡើងជណ្តើរដោយស្រួល) អាឈ្មុះ ឡើងជណ្តើរហើយចាប់ផ្តើមធ្វើការ ចំណែកអាប្រាជ្ញឈរនៅពីក្រោមពីរបីកាំ ដៃម្ខាងកាន់កំប៉ុងថ្នាំ ។ ធម្មនុញ្ញគ្រប់មាត្រា ត្រូវសរសេរលើជញ្ជាំងខ្មៅដោយថ្នាំសជាអក្សរធំ ៗ ដែលគេអាចមើលពីចម្ងាយបាន ។

វាអានដូចតទៅ :

## ធម្មនុញ្ញ

មាត្រា១ . - អ្វីដែលមានជើងពីរជាសត្រូវ

មាត្រា២ . - អ្វីដែលមានជើងបួននិងមានស្លាបជាមិត្ត

មាត្រា៣ . - សត្វមិនត្រូវស្លៀកសំពត់

មាត្រា៤ . - សត្វមិនត្រូវដេកលើគ្រែ

មាត្រា៥ . - សត្វមិនត្រូវផឹកស្រា

មាត្រា៦ .- សត្វមិនត្រូវសម្លាប់សត្វគ្នាឯង

មាត្រា៧ .- សត្វទាំងអស់ស្មើគ្នា

មាត្រាទាំងអស់ត្រូវបានសរសេរឡើងយ៉ាងប្រណីតមានខុសខ្លះតែមិនសំខាន់ទេ ។ រីឯអក្ខរាវិរុទ្ធត្រឹមត្រូវល្អទាំងអស់ ។ អាឈ្មុះអានឡើងវិញខ្លាំងៗដើម្បីឱ្យអ្នកទាំងអស់ឮ ។ សត្វទាំងអស់យល់ព្រមឥតមានជំទាស់ត្រង់ណាឡើយ ។ ចំណែកសត្វដែលឆ្លាត បានទន្ទេញមាត្រាទាំងអស់ចាំជាស្រេច ។

"ឥឡូវសមមិត្ត - អាឈ្មុះនិយាយដោយគ្រវាត់ជក់សរសេរចោល - ចូរយើងនាំគ្នាទៅច្រូតស្មៅ ដើម្បីទុកជាកិត្តិយស ។ យើងត្រូវធ្វើការឱ្យបានលើសជាងអាស្វិតនិងគ្នីគ្នាវា" ។

លុះព្ធូច្នោះ គោទាំងបីដែលមិនសូវស្រួលខ្លួនយូរមកហើយនោះក៏ស្រែកម៉ ដោយត្អូញត្អែរថា គ្មាននរណារឹតទឹកដោះវាជាង២៤ ម៉ោងមកហើយ ហើយដោះវាតឹងស្ទើរបែក ។ គិតមួយស្របក់មក ជ្រូកក៏បញ្ជាឱ្យរកប៉ោតហើយក៏ចាប់ផ្តើមរឹតទឹកដោះដោយដៃទាំងពីរយ៉ាងថ្នឹក ។ រឹតតែបន្តិច ក៏បានទឹកដោះពេញប្រាំប៉ោត ។ សត្វទាំងឡាយឈរមើលដោយផ្ចិតផ្ចង់ ។



"តើយើងនឹងយកទឹកដោះនេះទៅធ្វើអ្វី?" សត្វមួយស្រែកសួរឡើង ។

"អញធ្លាប់ឃើញអាស្វិត យកទៅលាយឱ្យអញស៊ី" ។ មាន់មួយឆ្លើយភ្លាម ។ "គួរកុំគិតពីអាទឹកដោះនេះ" ។ អាឈ្មុះស្រែកឡើងហើយសម្លឹងមើលទៅទឹកដោះគោ "ទុកវាសិនទៅការច្រូតស្មៅវាសំខាន់ជាង! នែ! អាសំឡីជួរឯងនាំគ្នាយើងទៅមុនចាំអញទៅតាមក្រោយ ។ ទៅមុនចុះសម្លាញ់ ការច្រូតកំពុងតែចាំយើង" ។

សត្វទាំងឡាយនាំគ្នាដើរតំរង់ទៅវាលស្មៅ ហើយក៏ចាប់ផ្តើមច្រូត ។ ដល់ត្រឡប់មកវិញនៅពេលល្ងាច វាទាំងអស់គ្នាដឹងថាមានគេលួចទឹកដោះគោអស់ ។

## ជំពូក ៣

គេធ្វើការ បែកញើសដើម្បីច្រូតនិងអូសស្មៅយកបកទុក លទ្ធផលបានគាប់ប្រសើរលើសពីការស្មាន ។ នេះជាជោគជ័យដ៏ធំមួយរបស់ពួកគេ ។ ពួកគេតែងជួបប្រទះនឹងឧបសគ្គជាច្រើនក្នុងការប្រកបការងារ ព្រោះកិច្ចការទាំងនេះកើតមានឡើងសំរាប់តែមនុស្ស ។ ហ្នឹងហើយពួកគេមានការពិបាកយ៉ាងខ្លាំង ព្រោះជួនកាលកិច្ចការខ្លះបង្ខំឲ្យគេឈរលើជើងក្រោយទាំងពីរដូចមនុស្ស ។ តែជ្រូកវាឆ្លាត វាចេះត្រិះរិះរកមធ្យោបាយដោះស្រាយបានទាំងអស់ ។ សេះស្គាល់វាលស្មៅស្ទើរតែគ្រប់កន្លែង ហើយដោយពិតទៅវាចេះច្រូតនិងប្រមូលស្មៅពូកែជាងពូស្មិតនិងគ្នីគ្នាគាត់ទៅទៀត ។ ជ្រូកមិនសូវចេះធ្វើការទេ វាគ្រាន់តែឲ្យបញ្ជានិងត្រួត ។ ដោយវាមានប្រាជ្ញាជាងសត្វដទៃ វាត្រូវតែកាន់តំណែងកំពូលជាក្រុមអ្នកដឹកនាំ ។ អាព្រូញនិងមីកណ្ដូបសេះ ចេះរៀបចំខ្លួនវាដាក់ខ្សែចងរទេះឬនាស់ (ជន្ទ្រញនិងបង្ហៀរត្រូវឈប់ប្រើចាប់ពីថ្ងៃនេះតទៅ) ហើយអូសជុំវិញវាលស្មៅ ដោយមានជ្រូកនៅពីក្រោយ គ្រាន់តែឲ្យបញ្ជាដូចជា: " ទៅមុខ " ឬ



"ទៅក្រោយ" ។ សត្វនីមួយៗ សុទ្ធតែបានធ្វើការ ខ្លះត្រឡប់ស្មៅ ខ្លះទៀតប្រមូលស្មៅ ។ សូម្បីតែទានិងមាន់ក៏ជួយគេដែរ វាដើរទៅវិញទៅមកកណ្ដាលថ្ងៃ ពាំស្មៅយកទៅទុកពេញមួយថ្ងៃ ។

ការច្រូតកាត់បានចប់សព្វគ្រប់ក្នុងរយៈពេលពីរថ្ងៃ ស៊ីពេលតិចជាងពូស្មិតនិងគ្នីគ្នាគាត់ទៅទៀត ។ តាមពិតកិច្ចការនេះ ជាសញ្ញានៃប្រតិបត្តិការមួយយ៉ាងធំដែលមិនដែលកើតមានឡើយនៅក្នុងភូមិសប្រែង ។ គ្មានការខូចខាតនិងខ្ជះខ្ជាយឡើយ ។ សូម្បីតែកំទេចស្មៅតូចមួយក៏ត្រូវទានិងមាន់ពាំយកទៅទុកដែរ ។ ម្យ៉ាងទៀតគ្មានសត្វណាមួយលួចស៊ីទេ ។ រដូវក្ដៅបានផុតទៅ ម្នាក់ៗមានការធ្វើហួត ។ សត្វទាំងអស់មានការរំភើបចិត្ត និងសប្បាយក្នុងកិច្ចការដែលវាពុំដែលនឹកនាសោះនោះ ។ ចំណីមានឱជារសឆ្ងាញ់ខុសពីមុន ព្រោះឥឡូវចំណីនោះជាកម្មសិទ្ធិរបស់វា ។ វាបានបង្កើតខ្លួនវា សម្រាប់ខ្លួនវា ខុសពីមុនដែលជាចំណីបំប៉នដោយម្ចាស់អសប្បុរស ។ នៅពេលដែលមនុស្សឥតតម្លៃនិងរស់នៅដោយសារកម្លាំងគេ បានបាត់ទៅហើយ ប្លូបចំណីហាក់ដូចជាបានបរិបូណ៌គ្រប់ៗគ្នា ។ ការសប្បាយក៏មានច្រើន ថ្វីបើសត្វទាំងនោះ ពុំទាន់មានការពិសោធន៍ក៏

ដោយ ។ ចំណីសត្វបានច្រើន ដូចជាសោរស្រូវពោតជាដើម វាត្រូវប្រឡេះពោតចេញតាមរបៀបចាស់ គឺផ្ទុំ ព្រោះវាគ្មានប្រដាប់សំរាប់ប្រឡេះ ។ តែក្រោយការដឹកនាំរបស់អាព្រួញ ជ្រូកប្រឡេះពោតដោយកម្លាំងបាយ ។ ឥឡូវអ្នកណាក៏សរសើរអាព្រួញ ដែលពីដើមធ្វើការច្រើនជាងគេជាងឯង ហើយឥឡូវធ្វើការបីដងលើសដើមទៅទៀត ។ កិច្ចការទាំងពួងក្នុងស្រែត្រូវធ្លាក់ក្នុងកណ្ដាប់ដៃអាព្រួញទាំងអស់ ។ ពីព្រឹកទល់ព្រលប់វារុស វារុញរទេះ និងធ្វើតែការណាដែលពិបាក ។ វាបានពឹងឲ្យមាន់ជល់មួយចាំដាស់វាឲ្យភ្ញាក់កន្លះម៉ោងមុនគេ ហើយចាប់ធ្វើការដែលត្រូវបង្ហើយនិងប្រញាប់ មុនគេឯងទាំងអស់ ។

វាបានជួយដោះស្រាយបញ្ហាជាច្រើន ហើយថែមទាំងបើកដំកើងគំនិតថ្មី ដែលវាប្រកាន់ទុកជាមេរៀនរបស់វាយ៉ាងខ្ជាប់ខ្ជួនគឺ : "អញត្រូវធ្វើការឲ្យកាន់តែច្រើន" ។

ម្នាក់ៗបានធ្វើការទៅតាមសមត្ថភាពរៀងៗខ្លួន ។ ទានិងមាន់បានជួយរើសគ្រាប់ពោត ធ្វើឲ្យបានចំណេញបួនប្រាំតៅក្នុងពេលប្រឡេះពោតម្ដងៗ ។ ឥតមានអ្នកណាលួចត្បិចត្បួរអំពីចំណីឡើយ ។ ការឈ្លោះ ប្រដាល់ប្រកប់ប្រណែន ដែលពីដើមធ្លាប់មាន ឥឡូវបាត់អស់រលីង ។ គ្មាន



នរណាគេចវេះពីកិច្ចការទេ ហើយស្ទើរជាគ្មាននរណាត្អូញសោះ ។ មានតែមីប្រផេះមួយទេ ដែលក្រោកមិនទាន់គេ ហើយធ្វើការក៏មិនហ៊ើសរហូន ហាក់ដូចជាបានជួយជុំចងជាប់នឹងជើងវា ។ ចំណែកអាកប្បកិរិយារបស់ឆ្មាក៏គួរឲ្យកត់សំគាល់ដែរ ។ ព្រោះឲ្យតែពេលណាបានការ វាច្រើនតែរត់គេចបាត់ ។ វាពួនបាត់រាប់ម៉ោង ឃើញមុខតែក្នុងពេលបាយ ឬពេលល្ងាចដែលគេបានបង្ហើយកិច្ចការអស់ហើយ ។ វាធ្វើដូចជាមិនដឹងមិនឮអ្វីសោះ ។ តែវាចេះធ្វើពុត មាយាស្រែកយំគួរឲ្យអាណិតនិងជឿទាំងស្រុង។ អាភ្លើ លាកញ្ចាស់ដូចជាគ្មានប្ដូរចិត្តគំនិតអ្វីសោះ តាំងពីបដិវត្តន៍មក ។ វាធ្វើការតាមរបៀបយឺត ហើយចចេសដូចជំនាន់មុន ។ វាមិនដែលគេចវេះមែនតែក៏មិនដែលធ្វើការអ្វីដែរ ។ បើគេសួរវាពីប្រយោជន៍និងលទ្ធផលនៃបដិវត្តន៍ វាឆ្លើយថាគ្មានយោបល់។ បើសួរថា តើវាសប្បាយចិត្តជាងមុនឬទេ វាឆ្លើយត្រឡប់មកវិញថា : "សត្វលា មានជីវិតវែងណាស់ ពួកអ្នករាល់គ្នាមិនដែលប្រទះឃើញខ្មោចលាទេ" ។ សត្វទាំងឡាយស្ដាប់ហើយក៏ពេញចិត្តនឹងសំដីរបស់វានេះទៅ ។

ថ្ងៃអាទិត្យជាថ្ងៃសំរាក ។ បាយព្រឹកត្រូវពន្យារពេលមួយម៉ោង ។ ក្រោយពេលបាយ សត្វទាំងអស់ត្រូវចូលរួមក្នុងពិធី

ដែលគេតែងរៀបចំឡើងរាល់អាទិត្យ ។ ដំបូង គឺពិធីលើកទង់ ។ អាសំឡីរើសបានក្រណាត់ក្រមាលតុពណ៌ខៀវខ្ចីរបស់ប្រពន្ធពូស្មិតហើយវាគូររូបក្រចកសេះ និងស្នែងពណ៌សលើផ្ទាំងសំពត់នោះ ។ នេះជាទង់បដិវត្តន៍របស់វា ។ រាល់ព្រឹកថ្ងៃអាទិត្យគេត្រូវបង្ហូតទង់នេះនៅមុខផ្ទះ ។

"ពណ៌ខៀវខ្ចី តំណាងវាលស្មៅនៃស្រុកយើង" អាសំឡីពន្យល់ "ចំណែកឯក្រចកសេះនិងស្នែងជាសញ្ញានៃសាធារណរដ្ឋរបស់យើងក្រោយពីបានរំលំរបបមនុស្ស" ។

លុះលើកទង់រួច សត្វទាំងអស់គ្នាក៏ចូលទៅក្នុងជង្រុកធំដើម្បីធ្វើមហាសន្និបាតដែលវាហៅថា "មីទីង" ។ ពេលនេះហើយដែលផែនការ សម្រាប់អាទិត្យក្រោយត្រូវយកមកជជែក ។ សេចក្ដីសម្រេចចិត្តទាំងឡាយ ត្រូវយកមកពិនិត្យនិងពិភាក្សា ។ រាល់ដងគេសង្កេតឃើញថាជ្រូកជាអ្នកចូលចិត្តស្នើសេចក្ដីសម្រេចចិត្ត ។ សត្វឯទៀតចាំតែបោះឆ្នោត ។ អាសំឡី និង អាឈ្មុះ ធ្វើសកម្មភាពច្រើនជាងគេក្នុងពេលប្រជុំម្ដងៗ ។ តែតាមការសង្កេត គេឃើញថាអាពីរនាក់នេះច្រើនតែមានយោបល់ខ្វែងគ្នា : បើអាមួយស្នើ អាមួយមុខជាប្រឆាំងជានិច្ច ថ្វីបើសេចក្ដីសម្រេចនោះបានបោះឆ្នោតរួចហើយនិងមិនត្រូវឲ្យមានការជំទាស់ក៏ដោយ ។



ដូចជា ក្នុងរឿងមួយដែលបានសំណើចង់បង្កើតផ្ទះសំរាក នៅក្រោយចំការ សំរាប់សត្វណាដែលចូលវ័យជរា ធ្វើការលែងកើត ។ ពេលនោះមានកើតការទាស់ទែងគ្នារវាងអាសំឡី និងអាឈ្មុះអំពីការកំណត់អាយុពូជសត្វគ្រប់ប្រភេទ ។

មហាសន្និបាតច្រើនបញ្ចប់ដោយចម្រៀង "បដិវត្តន៍" ហើយនៅពេលរសៀល សត្វទាំងឡាយអាចសម្រាកបាន។ ជ្រូកបានយកបន្ទប់ដាក់សម្ភារៈធ្វើជាសេនាធិការរបស់វា ។ ពេលយប់វានាំគ្នារៀនចំណេះជាងដែក ជាងឈើនិងចំណេះផ្សេងៗទៀត តាមសៀវភៅដែលវាប្រមូលបានមកពីផ្ទះពូស្មិត ។

អាសំឡី រវល់ណាស់ក្នុងការរៀបចំសត្វទាំងអស់ឲ្យទៅជាក្រុមៗហៅថាគណៈកម្មការ ។ វាមិនដែលនឿយហត់ក្នុងកិច្ចការនេះឡើយ ។ វាបង្កើត "គណៈកម្មការបង្កើនពង" សម្រាប់ពួកមាន់ "គណៈកម្មការបោសសំអាត" សម្រាប់គោ "គណៈកម្មការដុសខាត់គំនិត" សម្រាប់ហ្វឹកហ្វឺនកណ្ដុរនិងទន្សាយដែលជាសត្វព្រៃ "គណៈកម្មការបង្កើនរោម" សម្រាប់ចៀមនិងគណៈកម្មការឯទៀតៗ ។ ម្យ៉ាងទៀតវាបានបង្កើតសាលារៀនអាននិងសរសេរ ។

សំរេចសំរួចទៅ គំរោងការទាំងនេះធ្លាក់ទឹកទាំងអស់ ។

ដូចជាគំរោងហ៊ឹកហ្វឺនសត្វព្រៃឲ្យចេះមានរបៀបរបប និងសណ្ដាប់ធ្នាប់ ។ ដល់ធ្វើបានបន្តិចទៅ ឃើញថាសត្វព្រៃអស់នោះនៅតែមានអាកប្បកិរិយាដដែល ហើយបើកាលណាសត្វទាំងពួងទទួលស្គាល់វា វានឹងយកឱកាសនោះដើម្បីបំពើប្រយោជន៍ផ្ទាល់ខ្លួនតែម្ដង ។ ឆ្មាបានស្ម័គ្រចិត្តចូលបំរើក្នុងគណៈកម្មការដុសខាត់គំនិត បានតែពីរបីថ្ងៃ ហើយបាត់មុខតែម្ដងទៅ ។ ជួនកាលគេឃើញវាអង្គុយលើដំបូល និយាយលេងជាមួយសត្វចាបយ៉ាងព្រងើយ ។ វាប្រាប់ទៅចាបថា ឥឡូវសត្វទាំងអស់ជាមិត្ត ហើយបើចាបណាមួយចង់ចូលក្នុងចលនានេះ នោះនឹងអាចហើរមកទំជិតជើងវាបាន ។ ក៏ប៉ុន្តែមិនដែលមានចាបណាមួយមកជិតវាឡើយ ។

ថ្នាក់រៀនអាននិងសរសេរដូចជាមានជោគជ័យ ។ មកដល់រដូវមួយទៀត សត្វស្ទើរតែទាំងអស់ចេះអាននិងចេះសរសេរបន្តិចបន្តួច ។ ចំពោះជ្រូក វាចេះអាននិងសរសេរយ៉ាងជំនាញ ។ ឥឡូវនេះឆ្កែចេះអានគ្រាន់បើ តែមិនចូលចិត្តអានអ្វីទាំងអស់ក្រៅពីធម្មនុញ្ញ ។ មីភ្លុកពពែញីចេះអានស្ទាត់ជាងឆ្កែ ហើយឧស្សាហ៍អានអត្ថបទកាសែតដែលវារើសបានពីក្នុងធុងសំរាមឲ្យសត្វដទៃទៀតស្ដាប់ ។ អាភ្លី



ចេះមើលស្ទាត់ដូចជ្រូកទាំងឡាយ ក៏ប៉ុន្តែមិនសូវហ៊ឹកហ្វឺនខ្លួនឯងតទៅទៀតទេ ។ ពីព្រោះតាមយោបល់វា វាថាដូចជាគ្មានអ្វីសំខាន់នឹងអានទេ ។ មីកណ្ដូបសេះចេះអស់តួអក្សរ តែមិនចេះប្រកប ។ អាព្រួញនៅងាប់ត្រឹមអក្សរ "គ" ។ វាយកជើងគូសអក្សរលើដី ឈរផ្ញើងមើលអក្សរនីមួយៗ ត្រចៀកបះទៅក្រោយ ជួនកាលគ្រវីក្បាលខំប្រឹងទន្ទេញឲ្យចាំតែដូចជាគ្មានបានផលអ្វីសោះ ។ វាចេះហើយច្រើនតែភ្លេចទៅវិញ ។ ដូច្នេះ ឥឡូវនេះវាចេះត្រឹមតែអក្សរ "គ" ដែលវាសរសេរចុះឡើងរាល់ថ្ងៃដើម្បីកុំឲ្យភ្លេច ។ មីប្រផេះប្រកែកមិនព្រមរៀនអ្វីក្រៅពីអក្សរដែលមានក្នុងឈ្មោះវាទេ ។ វាយកមែកឈើងាប់មកផ្គុំជាអក្សរឈ្មោះវាហើយបេះផ្កាពីរបីមកលំអ រួចដើរជុំវិញមើលឈ្មោះវាដោយសេចក្ដីរីករាយ ។

សត្វឯទៀតរៀនបានត្រឹមតែអក្សរ "ក" ។ ចំណែកអាល្ងង់ដូចជាពពែបាន់និងទា វាមិនទាំងចាំនូវធម្មនុញ្ញដែលមានមាត្រាតែប្រាំពីរផង ។ ក្រោយពីបានត្រិះរិះអស់ពេលជាច្រើនមក អាសំឡី ក៏បានសម្រេចបង្រួញធម្មនុញ្ញនោះឲ្យមកនៅតែត្រឹមឃ្លាមួយ៖ "ជើងបួនល្អ ជើងពីរអាក្រក់" ដែលវាសន្មតថាជាគោលគំនិតធំនៃលទ្ធិសត្វនិយម ។ សត្វ

ណាបានយល់ឃ្លានេះច្បាស់ មុខជាបានគេចផុតពីឥទ្ធិពលនៃមនុស្ស ។ មុនដំបូងសត្វស្លាបទាំងអស់មិនយល់ស្របតាមទេព្រោះនឹក។ ទៅពួកវាមានជើងពីរដូចមនុស្សដែរ តែអាសំឡីខំពន្យល់ដូចតទៅ :

"សមមិត្ត ស្លាបឯងជាអវយវៈនៃការធ្វើដំណើរមិនមែនជាអវយវៈសម្រាប់ចាប់កាន់ទេ ។ ដូច្នេះស្លាបអ្នកត្រូវគិតដូចជាជើង ។ វាខុសពីដៃមនុស្សដែលវាប្រើប្រាស់សំរាប់ប្រព្រឹត្តអំពើអាក្រក់នានា" ។ សត្វស្លាបទាំងឡាយមិនសូវយល់ន័យនៃពាក្យព[illegible]ប់របស់អាសំឡីនេះទេ តែវាសុខចិត្តទទួលព្រម ហើយចាប់ពីពេលនោះមក សត្វទាំងឡាយខំទន្ទេញឃ្លាខាងលើនេះ ។ ពាក្យស្លោក "ជើងបួនល្អ ជើងពីរអាក្រក់" ក៏បានត្រូវគេសរសេរនៅលើជញ្ជាំងជង្រុក ដោយអក្សរធំៗ ពីលើមាត្រាទាំងប្រាំពីរនៃធម្មនុញ្ញ ។ នៅពេលដែលវាបានទន្ទេញចាំស្ទាត់ហើយ ពពែក៏កាន់តែស្រឡាញ់ភាសិតនេះឡើង ។ រាល់ពេលដែលវាដេកលេង កណ្ដាលវាលស្មៅវាតែងតែស្រែកពាក្យនេះ "ជើងបួនល្អ ជើងពីរអាក្រក់ ! ជើងបួនល្អ ជើងពីរអាក្រក់ !" ពីរបីម៉ោងដោយឥតនឿយហត់អ្វីឡើយ ។

អាឈ្មុះមិនសូវពីរវល់នឹងគណៈកម្មការដែលអាសំឡីបាន



បង្កើតនោះទេ ព្រោះវាជឿថា បើចង់ឲ្យមានប្រយោជន៍ ការអប់រំត្រូវធ្វើឡើងសម្រាប់តែសត្វតូចៗមិនមែនសំរាប់បង្រៀនពួកអាធំៗទេ ។ ក្រោយពីបានរួចការច្រូតកាត់ហើយ មីម្រេចនិងមីព្រុះ បានសម្រាលកូនបានប្រាំបួន ។ បន្តិចមក អាកូនឆ្កែត្រូវផ្ដាច់ដោះពីមេវា ។ អាឈ្មុះយកវាទៅទុកឆ្ងាយពីមេវា ព្រោះវាជឿថាត្រូវតែឲ្យវាបានទទួលការអប់រំ ។ វាយកទៅលាក់ទុកលើធ្នើខ្ពស់មួយ ។ ហើយដើម្បីឡើងទៅដល់ គេត្រូវប្រើជណ្ដើរ ។ កន្លែងនេះស្ងាត់ពីមុខពីមាត់គេឯងម៉្លោះហើយគ្មានសត្វណាដឹងឮអំពីរឿងនេះទេ ។

រឿងទឹកដោះគោដែលចេះតែបាត់ ឥឡូវគេទើបនឹងដឹងថាជ្រូកលួចយកទៅផឹក ។ ឥឡូវនេះដល់រដូវផ្លែឈើទុំ ។ វាលស្មៅក្រោលពាសពេញទៅដោយផ្លែឈើទុំជ្រុះដោយត្រូវខ្យល់ ។ សត្វទាំងអស់សង្ឃឹមថានឹងបានចំណែកស្មើៗគ្នា ។ ថ្ងៃមួយមានបញ្ជាពីលើមកថា ផ្លែឈើទុំៗ ដែលជ្រុះត្រូវរើសហើយប្រមូលសម្រាប់ជាចំណីជ្រូក ។ ពេលនោះសត្វទាំងឡាយ បញ្ចេញពាក្យរអ៊ូរទាំ តែឥតបានការ ។ ជ្រូកគេយល់ស្របទាំងអស់គ្នា សូម្បីតែអាសំឡីនិងអាឈ្មុះក៏ស្របតាមដែរ ។ អាប្រាជ្ញមានភារៈពន្យល់សត្វទាំងឡាយអំពីរឿងនេះ ។ "សមមិត្ត" អាប្រាជ្ញស្រែកឡើង "ពួកឯងកុំ

ស្មានថាពួកជ្រូកគេធ្វើនេះ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ។ ពួកយើងមិនចូលចិត្តទឹកដោះគោនិងផ្លែឈើទុំទាំងនោះទេ ។ តែគោលបំណងធំរបស់យើងគឺសុខភាពល្អ ។ វិទ្យាសាស្ត្របានថែងថា ទឹកដោះគោនិងផ្លែឈើមានជាតិសំរាប់ឲ្យសត្វជ្រូកមានសុខភាពមាំមួន ។ យើងជ្រូកជាអ្នកប្រើប្រាជ្ញា ។ កិច្ចការទាំងអស់នៅក្នុងភូមិនេះ ត្រូវពួកជ្រូកធ្វើ ។ ថ្ងៃយប់ យើងជ្រូកជាអ្នកមើលការខុសត្រូវដល់សុខទុក្ខរបស់ឯងទាំងអស់គ្នា ។ ដោយសារពួកឯងទាំងអស់គ្នានេះហើយ ដែលជ្រូកបង្ខំចិត្តផឹកទឹកដោះគោនិងស៊ីផ្លែឈើ ។ តើវានឹងទៅជាយ៉ាងម៉េចទៅវិញ បើសិនជាយើងជ្រូក ធ្វើការមិនកើត?។

អាស្វិតនឹងត្រឡប់មកវិញ ! ពិតមែនហើយ អាស្វិតនឹងត្រឡប់មកវិញ ! ហើយមុខជា...” អាប្រាជ្ញស្រែកព្រមទាំងដើរចុះឡើង គ្រវីគ្រវាត់កន្ទុយទៅមក “មុខជាក្នុងចំណោមឯងទាំងអស់គ្នានេះ គ្មាននរណាមួយចង់ឃើញមុខអាស្វិតឡើយ” ។

រឿងមួយដែលសត្វអស់នេះដឹងហើយយល់ គឺមិនចង់ឃើញមុខពូស្វិតចៅហ្វាយចាស់ ។ និយាយដល់រឿងនេះឡើង សត្វទាំងអស់រកអ្វីតបតពុំបានឡើយ ។ ការទុកឲ្យពួកជ្រូកបានសុខភាពល្អដូចជាការប្រសើរនិងចាំបាច់ ។



ដូច្នេះ ការងាររបស់គ្នាពេលក្រោយ ចាប់ពីថ្ងៃនេះតទៅ ទឹកដោះគោនិងផ្លែឈើទុំៗ ជ្រុះក៏ដោយ នៅលើដើមក៏ដោយ ត្រូវរក្សាទុកឲ្យពួកជ្រូក ។

# ជំពូក ៤

នៅចុងរដូវក្តៅ ដំណឹងនៃបដិវត្តន៍នៅភូមិសម្រែងបានឮសុះសាយដល់ភូមិជិតខាង ។ រាល់ថ្ងៃ អាសំគ្លីនិងអាឈ្មុះប្រើព្រាបឡប់បំពេញបេសកកម្មនៅភូមិជិតឆ្ងាយ ដើម្បីពន្យល់អំពីបដិវត្តន៍និងបង្រៀនចំរៀង : "បដិវត្តន៍" ។

ចាប់ពីពេលកើតហេតុមក គេឃើញពូស្មិតអង្គុយនៅក្នុងតៀមស្រារ៉ាយរ៉ាប់ប្រាប់គេឯងពីរឿងខ្ទាចផ្សារបស់គាត់ពីអយុត្តិធម៌ដែលកើតឡើងដោយពួកអាសត្វចង្រៃបណ្តេញគាត់ ។ អ្នកទាំងឡាយមានការឈឺចាប់ជាមួយគាត់ដែរ តែដូចជាគ្មានជួយអ្វីដល់គាត់សោះ ។ ម្នាក់ៗគិតតែពីរិះរកមធ្យោបាយដើម្បីកំរៃរៀងៗខ្លួន ។ ជាគ្រោះល្អរបស់ពូស្មិត អ្នកដែលនៅជិតភូមិគាត់ចេះតែឈ្លោះគ្នា ។ ភូមិមួយនោះឈ្មោះ "ទួលក្រាំងសៀម" ជាភូមិធំតែត្រូវគេទុកចោលឥតបានធ្វើស្រែចំការអ្វីឡើយ ហើយព្រៃឈើក៏ដុះពាសពេញ ។ ម្ចាស់ភូមិគឺពូថង ។ គាត់ជាមនុស្សខ្ជិល គិតតែបរបាញ់និងស្ទូចត្រី ។ ភូមិមួយទៀតឈ្មោះ "ត្រពាំងស្រគី" មានទំហំតូចតែស្អាត ព្រោះមានការថែទាំល្អ ។ ពូយៀងម្ចាស់



ភូមិនោះ ជាមនុស្សរឹងរូសពិបាកសៀក ពាក់រឿងការក្តីនៅតុលាការ ហើយគេអះអាងថាគាត់ពូកែខាងជំនួញដែលមិនស្មោះត្រង់ជាមួយអ្នកដទៃ ។ ពូ "ថង" និងពូ "យៀង" ជាសត្រូវនឹងគ្នា ហើយមិនដែលមានពេលណាមួយដែលអ្នកទាំងពីរបានស្រុះស្រួលគ្នាលើរឿងអ្វីមួយឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏គាត់ទាំងពីរមានការព្រួយបារម្ភច្រើនចំពោះព្រឹត្តិការណ៍ដែលទើបនឹងកើតមាននៅភូមិសម្រែង ។ ទាំងពីរនាក់ខំប្រឹងប្រើគ្រប់មធ្យោបាយ ដើម្បីកុំឲ្យដំណឹងបដិវត្តន៍ឮដល់សត្វទាំងឡាយដែលនៅក្នុងភូមិគាត់ ។ ដំបូងគាត់សើច ហើយមិនជឿថាសត្វអាចត្រួតត្រាភូមិដោយខ្លួនឯងបានទេ ។ តែគាត់ជឿថា ហេតុការណ៍នោះនឹងបានចប់ក្នុងរវាងមួយយប់ប៉ុណ្ណឹង ថាសត្វនៃភូមិសម្រែង (គាត់មិនព្រមហៅភូមិ "វិមានសត្វ" ទេ) កំពុងវាយប្រតប់គ្នា ហើយថាមុខជាស្លាប់ដោយអត់បាយមិនខាន ។ លុះដល់ឮថាសត្វអស់ទាំងនោះឥតមានការស្រេកឃ្លានអ្វីឡើយ ពូថងនិងពូយៀង ក៏ប្រែសំដីបែរជានិយាយពីអំពើផ្តេសផ្តាសដែលពួកសត្វនៅភូមិសម្រែងបានបង្កើតឡើង ។ គាត់ទាំងពីរនាក់ជឿថា សត្វអស់នោះមុខជាសម្លាប់គ្នាឯងស៊ីនិងពាក់ញីជាមួយគ្នាដែលជាអំពើប្រឆាំងនិងច្បាប់ធម្មជាតិ ។

គ្មាននរណាដឹងរឿងពិតទេ ។ ពាក្យចចាមអារាមពីភូមិមួយដែលថាសត្វបានបណ្ដេញចៅហ្វាយ ហើយចាត់ចែងកិច្ចការខ្លួនឯងនៅតែបេចញហើយការរំជើបរំជួលខ្លះបានកើតឡើងលើផ្ទៃប្រទេស ។ គោឈ្មោលដែលគេអាចដឹកបានក៏ក្លាយទៅជាកាចសាហាវ ពពែហែករបងចេញមកក្រៅស៊ីបន្លែ គោញីទាត់ធុងទឹកចោល ចំណែកសេះក៏លែងព្រមឲ្យគេជិះ ។

ចំរៀង "បសុវគ្គន៍" ក៏បានត្រូវផ្សាយទៅគ្រប់កន្លែងយ៉ាងរហ័សអស្ចារ្យ ។ មនុស្សមិនអាចទប់កំហឹងបានទេកាលណាឮចំរៀងនេះ ពីព្រោះគេថាវាជាចំរៀងផ្ដេសផ្ដាស។ គេមិនយល់ថាសត្វអាចប្រមូលគ្នាច្រៀងបទចំកួតនេះ បានសោះ ។ ហើយបើមានសត្វណាច្រៀងបទនេះវាមុខជាត្រូវបំពងដោយដំបងយ៉ាងដំណំមិនខាន ។ តែទោះជាយ៉ាងណាក៏ដោយក៏សត្វនៅតែច្រៀង ។ ក្អែកច្រៀងលើរបងព្រាបគំអូញលើដើមឈើ ។ វាច្រៀងតាមចង្វាក់នៃជាងដំដែកតាមសម្លេងកណ្ដឹងនិងស្គរនៃវត្តអារាម ។ កាលណាឮចំរៀងនេះហើយ មនុស្សទាំងអស់ភ័យរន្ធត់ នឹកឃើញដល់ទំនាយវិនាសកម្មរបស់ខ្លួន ។

នៅចុងរដូវមួយ ក្នុងពេលបេះពោតរួចស្រេចហើយព្រាប



មួយហ្វូងហោះហើរព្រួយឆ្ពាត់ហើយបន្ទាបខ្លួនលើពីភូមិស៊ីប្រដេញដោយក្ដីអន្ទះអន្ទែង ។ ពូស្មិតនិងជើងឈ្នួលព្រមទាំងក្រុមគាត់ប្រមាណប្រាំមួយនាក់ទៀតមកពីភូមិ ខុបព្រាំងសៀមនិងត្រពាំងស្រែក៏បានជិះរទេះតំរង់មកភូមិសប្រែង ។ ទាំងអស់គ្នាសុទ្ធតែមានដំបងមួយនៅដៃលើកលែងតែពូស្មិតដែលដើរពីមុខរទេះដោយកាន់កាំភ្លើង ។ អ្នកទាំងអស់នោះប្រាកដជាមកដណ្ដើមយកភូមិសប្រែងវិញ ។

សត្វទាំងអស់នៅក្នុងភូមិ ដែលដឹងជាមុនថារឿងនេះប្រាកដជាកើតមាននៅពេលណាមួយនោះ ក៏បានរៀបចំខ្លួនជាស្រេច។ អាសំឡីដែលបានធ្វើការសិក្សាលើយុទ្ធវិធីពីសៀវភៅមួយដែលវារើសបានក្នុងបន្ទប់ពូស្មិត បានទទួលភារៈជាអ្នកការពារ ។ វាឱ្យបញ្ជាយ៉ាងរហ័សហើយក្នុងមួយរំពេចប៉ុណ្ណោះ សត្វទាំងអស់ក៏បានទៅកាន់កន្លែងការពាររៀង ៗ ខ្លួន ។ លុះពូស្មិតនិងគ្នីគ្នាគាត់កាន់តែចូលមកជិតដល់មាត់ភូមិហើយ អាសំឡីក៏បើកការប្រយុទ្ធរបស់វាភ្លាម ។ ព្រាបទាំងអស់ប្រមាណ ៣៥ ហោះហួយឡើងទៅលើហើយបន្ទាបខ្លួនមកក្រោម ស្រែកទ្រហឹងរំលងកងលើក្បាលអ្នកទាំងនោះ។ ចំណែកឯក្ងានដែលលាក់ខ្លួនក្នុងរបង ក៏រត់ចេញមកចឹកជើងគេដែលបរអូសរទេះមក ។ នេះគ្រាន់តែជាការតទល់ដើម្បី

បង្កើតចលាចលច្របូកច្របល់ប៉ុណ្ណោះ ។ ក្នុងពេលដែលមនុស្សយកដំបងដេញវាយក្ងានច្រវេតច្រវាត់ អាសំឡីបើកការប្រយុទ្ធលើកទីពីរ ។ មីភ្លុក អាភ្លើនិងពពែទាំងអស់ដោយមានអាសំឡី នៅពីមុខ រត់យ៉ាងលឿនតំរង់ទៅហ្វូងមនុស្ស ហើយក៏ចាប់ប៉ុក ចាក់ ធាក់ វ៉ៃគ្រប់ទិសទី ។ អាភ្លើយកជើងប៉ើងត្រូវចំកន្ទុងធ្ងន់របស់មនុស្ស ។ តែមនុស្សដែលប្រើដំបងនិងស្បែកជើងបាតដែកគោលបានប្រៀបលើសគេ ។ ឃើញដូច្នោះ អាសំឡីស្រែកបញ្ជាឲ្យដកថយ ។ សត្វទាំងអស់ក៏ថយខ្លួនមកពួនក្នុងភូមិវិញ ។

មនុស្សស្រែកហ៊ោដោយជោគជ័យ ។ លុះបានឃើញសត្រូវដកថយចាញ់ហើយ គេក៏រត់ដេញតាមក្រោយ ។ នេះគឺជាការធ្លាក់ចូលក្នុងកលយុទ្ធមួយបែបរបស់អាសំឡី ។ ពេលដែលពួកសត្រូវបានចូលមកក្នុងភូមិហើយ អាសំឡីក៏បញ្ជាឲ្យសេះគោនិងជ្រូក ដែលបានសម្ងំចាំស្ទាក់នៅកៀនក្រោលចេញបករ័ធបំបែកហ្វូងមនុស្ស ។ ចំណែកអាសំឡី វារត់តំរង់ទៅពូស្មិត ។ លុះបានឃើញដូច្នោះហើយ ពូស្មិតក៏លើកកាំភ្លើងបាញ់ ។ គ្រាប់រត់កកិតខ្នងអាសំឡី ។ ពពែមួយដួលស្លាប់ ។ ក្នុងមួយរំពេចនោះ អាសំឡីលើកដុំថ្មមួយដុំចោលចំជើងពូស្មិត ធ្វើឲ្យគាត់ដួលលើគំនរអាចម៍ ហើយកាំភ្លើងក៏



ធ្លាក់ពីដៃ ។ ចំណែកអាព្រួញវិញ វាធាក់ប៉ើងពីក្រោយម្នាក់ និងលុះបុកត្រូវឡសរលើរ ។ វាធាក់ប៉ើងជើងយ៉ាងខ្លាំង ត្រូវក្បាលពួម្នាក់មកពីភូមិក្បែរក្រាំងគៀប យ៉ាងពេញទំហឹង ធ្វើឲ្យគាត់ដួលដេកជាប់បាត់នៅក្នុងភក់ ។ ឃើញដូច្នោះហើយ មនុស្សទាំងឡាយក៏រត់យកតែព្រះអាយុ ខ្លះក៏ដំបងចោលពីដៃ ។ អ្នកទាំងនោះភ័យស្លន់រត់ប្រសាច ឯសត្វទាំងអស់ក៏ចាប់រត់ដេញតាមពេញទីធ្លា ។ គេត្រូវសត្វធាក់ ចាក់ ប៉ើង វ៉ៃ ចឹក ខាំ ។ គ្មានសត្វណាមួយដែលនៅស្ងៀមហើយមិនឆ្លៀតឱកាសដើម្បីសងសឹកទេ ។ សូម្បីតែឆ្មាក៏បានជួយដែរ ។ វាលោតពីលើដំបូលមកឈរលើស្មាអ្នកគង្វាលគោម្នាក់ហើយខាំកទាល់តែស្រែកទ្រហោយំយ៉ាងរន្ធត់ ។ ពេលដែលទ្វាររបងបើកហើយ មនុស្សទាំងឡាយក៏នាំគ្នារត់ព្រួចចេញទៅក្រៅ ។ ក្នុងរយៈពេលប្រមាណប្រាំនាទី អ្នកទាំងនោះរត់ដកថយទៅតាមច្រកដែលគេបានចូលមកពីមុន ។ ឯហ្វូងក្ងានក៏តាមព្យាបាទ ដេញចឹកជើងគេរហូត ។

មនុស្សចេញទៅវិញអស់ហើយ នៅសល់តែម្នាក់ដែលត្រូវអាព្រួញធាក់ដួលផ្កាប់មុខកប់ក្នុងភក់ ។ អាព្រួញដើរទៅជិត ហើយចង់លើកគាត់ឡើង តែបុរសនោះនៅស្ងៀមឥតកម្រើកឡើយ ។

"វាស្លាប់បាត់ទៅហើយ" អាព្រួញពោលឡើងដោយសង្វេគ – "អញគ្មានបំណងដូច្នេះសោះ ។ អញភ្លេចថាដើម អញបានសុខតែឯក ។ តើនរណាខ្លះជឿថាអញចង់សម្លាប់គាត់នេះ?"

"អត់ទេ អាសម្លាញ់" – អាសំឡី ដែលត្រូវរបួសហើយ ដែលមានឈាមនៅតែស្រក់តាមមុខរបួសនោះនៅឡើយ ឆ្លើយតបមកវិញភ្លាមហើយថា – "សង្គ្រាម គឺសង្គ្រាម តែមនុស្សល្អត្រូវស្លាប់ទៅវិញ" ។

"អញគ្មានបំណងសម្លាប់នរណាទេ សូម្បីតែជីវិតមនុស្សក៏ទេដែរ" – អាព្រួញបន្ថែមដោយទឹកភ្នែករលីងរលោង ។

"មីប្រផេះបាត់ទៅណាហើយ" ម្នាក់ឧទានឡើង

មីប្រផេះបាត់ខ្លួនមែន ។ ការផ្អើលភិតភ័យកើតមានឡើង ។ សត្វទាំងអស់ជឿថា មីប្រផេះត្រូវរបួសឬក៏មនុស្សចាប់វាយកទៅជាមួយហើយ ។ តែក្រោយពីបានរកបន្តិចមក គេឃើញវាពួននៅក្នុងក្រោល បង្កប់ក្បាលក្នុងចំបើងឯណោះសោះ ។ វាតែងពួនមុនគេ ក្រោយដែលបានឮសូរកាំភ្លើងភ្លាម។ លុះត្រឡប់មកពីរកមីប្រផេះវិញ សត្វទាំងអស់ដឹងថាមនុស្សដែលខ្លួនស្មានថាស្លាប់ទៅហើយនោះ បានដឹងខ្លួនវិញនិងរត់បាត់ទៅហើយ ។ សត្វទាំងឡាយមកជួបជុំគ្នាវិញដោយ



រីករាយ ។ គេទាំងឡាយរៀបរាប់ពីសកម្មភាពអង់អាចរបស់គេក្នុងពេលប្រយុទ្ធដោយសំដីក្អេងក្អាងរៀងៗខ្លួន ។ ពិធីមួយសម្រាប់ទទួលជោគជ័យក៏បានត្រូវរៀបចំភ្លាម ដោយឥតបានគិតទុកជាមុន ។ ទង់ត្រូវបង្ហូតឡើងលើបង្គោល ចម្រៀង "បដិវត្តន៍" ក៏បានច្រៀងឡើងជាច្រើនដង ។ ពពែដែលត្រូវគ្រាប់ស្លាប់ត្រូវបានគេយកទៅកប់យ៉ាងឧឡារិក ដោយមានបាច់ផ្កាដាក់ពីលើផ្នូរផង។ អាសំឡីជាអ្នកធ្វើសុន្ទរកថាថ្លែងអំពីសេចក្ដីត្រូវការនិងការប្ដេជ្ញាចិត្តនៃសត្វទាំងឡាយក្នុងការបូជាជីវិតនៅពេលមានអាសន្ន ។ វាទាំងអស់គ្នាបានសម្រេចចិត្តបង្កើតគ្រឿងឥស្សរិយយសទាហាន "វីរជនថ្នាក់ទីមួយ" ។ ងារនេះនឹងត្រូវប្រគល់ទៅឲ្យ អាសំឡី និង អាព្រួញ ជាលើកដំបូង ។ វាជាមេដាយស្ពាន់ (វារកបានបន្ទះស្ពាន់នោះនៅក្នុងរោងជាង) តែត្រូវពាក់នៅថ្ងៃអាទិត្យ ឬថ្ងៃសម្រាក ។ មានឥស្សរិយយសមួយទៀតហៅថា "វីរជនទីពីរ" ដែលត្រូវប្រគល់ទៅពពែដែលបានបាត់បង់ជីវិតទៅហើយនោះ ។ មានការជជែកគ្នាច្រើន អំពីការរកឈ្មោះដាក់ការប្រយុទ្ធដែលទើបនឹងប្រព្រឹត្តរួចមកនេះ ។ ក្រោយពីបានវែកញែកយ៉ាងយូរមក សត្វទាំងអស់ក៏ឲ្យឈ្មោះប្រយុទ្ធនេះថា: "ប្រតិបត្តិការសឹកសម្រែងជ័យ" ព្រោះការតយុទ្ធគ្នាខ្លាំងក្លាបានកើត

កើតមាននៅកន្លែងនេះ ។ កាំភ្លើងដែលពួកស្អិតទម្លាក់ចោល បានត្រូវរកឃើញនៅក្នុងកក់ ហើយពួកវាដឹងថា មានគ្រាប់ សល់នៅក្នុងរោងផាង ។ វាយកកាំភ្លើងនោះមកតាំងក្រោម បង្គោលទង់ទុកជាអនុស្សាវរីយ៍ និងទុកបាញ់ពីរដងក្នុងមួយឆ្នាំ គឺថ្ងៃទី១២តុលាម្តង សម្រាប់បុណ្យខួបនៃ "ប្រតិបត្តិការសឹក សង្គ្រាមជ័យ" និងថ្ងៃរំលឹក "បដិវត្តន៍" ម្តង ។



## ចំពូក ៥

រដូវវស្សាមកដល់ហើយ មីប្រផេះកាន់តែមានអាកប្ប-កិរិយាប្លែកពីធម្មតា ។ វាទៅធ្វើការមិនទាន់ពេលរាល់ព្រឹក ដោយសំអាងថាវាពិបាកក្រោកពីព្រលឹមពេក និងដោយថា មិនស្រួលខ្លួន ថ្វីបើវាស៊ីបានក៏ដោយ ។ វាធ្វើពុតជា ឈឺហើយឈប់ធ្វើការ ដើរទៅឈរស្ងៀមនៅមាត់ត្រពាំង ផ្ទៀងផ្ទង់មើលមុខវាដែលឆ្លុះក្នុងទឹក ។ ប៉ុន្តែមានរឿងចម្លែក មួយបានកើតឡើង ។ ថ្ងៃមួយនៅពេលដែលវាកំពុងដើរ លេងក្នុងទីធ្លា បក់កន្ទុយចុះឡើងហើយទំពាស្មៅមួយបាច់គំ នៅក្នុងមាត់ មីកណ្តូបសេះដើរទៅជិតហើយសួរថា៖

"នែ មីប្រផេះ អញមានការមួយចង់សួរឯង ។ ព្រឹក មិញអញឃើញឯងឈរអើតក្បាលទៅរកភូមិ ទួលក្រាំង សៀម ឯណោះ ។ អញឃើញឈ្នួលម្នាក់របស់អាថង វា ឈរនៅខ្សែរបងដែរ ។ ថ្វីបើអញនៅឆ្ងាយក៏ដោយ អញ ក៏ឃើញច្បាស់ថា វាបាននិយាយជាមួយឯងហើយយកដៃ អង្អែលច្រមុះឯងលេងផង ។ តើរឿងនេះវាយ៉ាងម៉េច មី ប្រផេះ ?"

“ មិនមែនទេ អញអត់បានធ្វើអញ្ចឹងទេ ហើយវាក៏អត់បានធ្វើដូចអ្នកថាដែរ !” មីប្រផេះ ស្រែកតបដោយគ្រវីគ្រវាត់ខ្លួនព្រមទាំងយកជើងទន្ទ្រំដីផង ។

“ មីប្រផេះ មើលមុខអញឲ្យចំ ! តើអ្នកហ៊ានស្បថទេថាអានោះវាអត់បានរង្គើលច្រមុះអ្នក ? ”

“ មិនមែនទាល់តែសោះ ” មីប្រផេះបញ្ជាក់បន្ថែមដោយអៀនមុខ ហើយមួយស្របក់មកវាក៏ដាយរត់ចេញបាត់ទៅ ។ មីកណ្ដុរបសេះនៅតែឆ្ងល់ ។ វាមិនព្រមនិយាយប្រាប់នរណាឡើយ ។ ថ្ងៃមួយវាដើរពំរង់ទៅកន្លែងមីប្រផេះ ។ ដល់ហើយវាយកជើងឆ្កឹះគំនរចំបើង ហើយនៅពេលនោះស្រាប់តែវាឃើញស្ករផ្កាច្រើនដុំនិងកំណាត់បូផាច្រើនពណ៌ ។

បីថ្ងៃក្រោយមក មីប្រផេះបាត់ខ្លួន ។ ហើយជាច្រើនអាទិត្យបន្ទាប់មកគ្មាននរណាមួយដឹងថា វាទៅណាសោះ ។ សត្វព្រាបបានមករាយការណ៍ថាបានឃើញវានៅភូមិដែលពួកឧស្សាហ៍ទៅផឹកស្រា ។ គេបានឃើញវានៅជិតខ្ទង់ភ្លើងក្បែរផ្ទះមេឃុំ ។ មានមនុស្សម្នាក់ពាក់មុខក្រហមស្លៀកពាក់ដូចផ្ទាំទ្វារ អង្អែលច្រមុះហើយចាក់ស្ករវា ។ ខ្លួនវាមានពាក់គ្រឿងលំអ ហើយនៅក្បាលវាមានបូក្រហម ។ វាដូចជាសប្បាយណាស់ ។ នេះជាសេចក្ដីរាយការណ៍របស់



ព្រាប ។ ចាប់ពីពេលនោះមក សត្វទាំងអស់មិនដែលចេញឈ្មោះមីប្រផេះ ទៀតឡើយ ។

នៅខែមករា ធាតុអាកាសមិនស្រួលល្អ (នៅស្រុកត្រជាក់គឺមានធ្លាក់ទឹកកក) ដីរឹងដូចដែក ម៉្លោះហើយកិច្ចការនានាក្នុងស្រែចំការត្រូវផ្អាក ។ មីទីងជាច្រើនបានត្រូវរៀបចំឡើងនៅក្នុងជង្រុកធំ ។ ជ្រូករវល់រៀបចំផែនការសំរាប់រដូវខាងមុខ ។ ថ្វីបើវិធានការទាំងឡាយត្រូវតែដាក់ឲ្យអង្គប្រជុំបញ្ចេញយោបល់សិនមុននឹងយកទៅអនុវត្តក៏ដោយ ក៏សត្វទាំងអស់ហាក់ដូចជាទុកចិត្តទាំងស្រុងលើជ្រូក ក្នុងការដោះស្រាយបញ្ហានានានៅក្នុងភូមិ ។ កិច្ចការទាំងឡាយអាចបានលឿនទៅមុខច្រើន បើសិនជាគ្មានការខ្វែងយោបល់គ្នារវាងអាសំឡឹនិងអាឈ្មុះ ។ អាពីរនាក់នេះ ខ្វែងគំនិតគ្នាស្ទើរតែរាល់ដង ។ បើម្នាក់ឲ្យយោបល់ថាគួរដាំស្រូវ ម្នាក់ទៀតថាឲ្យដាំពោតវិញ ។ ហើយបើអាម្នាក់ថាគួរដាំស្ពៃ អាម្នាក់ទៀតថាដីនោះគ្មានជីជាតិសម្រាប់បន្លែទេ ។

ម្នាក់ ៗ សុទ្ធតែមានអ្នកគាំទ្រ ម៉្លោះហើយជួនកាលមានរហូតដល់ទៅឈ្លោះទាស់ទែងខ្វែងគំនិតគ្នាផង ។ អាសំឡីច្រើនតែឈ្នះគេទាំងអស់ព្រោះវាចេះនិយាយពីរោះ តែពេលខ្លះអាឈ្មុះក៏មានប្រៀបជាងម្ដងៗដែរ ។ ជាច្រើនលើកវាបាន

ទទួលការគាំទ្រពីពួកពពែ ។ ពពួកពពែនេះច្រើនតែស្រែកពាក្យស្លោក: "ជើងបួនល្អ ជើងពីរអាក្រក់" ដើម្បីរំខានគេឯង ។ វាបន្ទរក្នុងពេលអាសំឡីនិយាយម្តងៗ ។

អាសំឡី បានធ្វើការសិក្សាលើសៀវភៅបច្ចេកទេសមួយ ដែលវារើសបានពីបន្ទប់ពូស្និត ។ វាមានគោលការច្រើនក្នុងកិច្ចរៀបចំភូមិ ។ វានិយាយអំពីរបៀបទំនើប សំរាប់បង្ហូរទឹកភ្លូរ ឬជីដែក ។ វាបានរកឃើញវិធីយ៉ាងទំនើប សំរាប់ឱ្យសត្វទាំងឡាយជុះអាចម៍ដាក់លើស្រែ នៅតាមកន្លែងដែលបានរៀបចំមុនជាស្រេចដើម្បីឱ្យបានចំណេញពេលនិងកម្លាំង ។ ចំណែកអាឈ្មុះគ្មានប្លង់អ្វីនឹងគេទេ ។ វាលួចនិយាយប្រាប់គេឯងដោយស្ងាត់ៗថា ប្លង់អាសំឡីគ្មានខ្លាចទេ ហើយនាំឱ្យតែខាតពេលវេលាប៉ុណ្ណោះ ។ ការជជែកខ្វែងគ្នានេះចេះតែបានបន្តរឿងៗទៅទៀត ។ តែរឿងទាស់ទែងខ្លាំងជាងគេ គឺរឿងគ្រោងសង់រហាត់ខ្យល់ ។

នៅលើវាលស្មៅ មិនឆ្ងាយប៉ុន្មានពីជង្រុក មានទួលមួយខ្ពស់ជាងគេ មើលទៅហាក់ដូចជាកូនភ្នំមួយ ។ ក្រោយពីបានវាស់វែងនិងគូសវាសផែនទីមក អាសំឡីបានសម្រេចចិត្ត ថានឹងសង់រហាត់ខ្យល់នៅកន្លែងខ្ពស់នោះ ព្រោះអាចបង្កើតកម្លាំងអគ្គិសនីបាន ។ ភូមិនឹងបានភ្លើងព្រមទាំងកំដៅ



ផង ។ គេអាចប្រើវាដំណើរការ ម៉ាស៊ីនច្រូតស្មៅ ម៉ាស៊ីនចិតបន្លែ និងម៉ាស៊ីនរឹតទឹកដោះគោបាន ។ សត្វទាំងឡាយមិនដែលបានឮពាក្យទាំងនេះពីមុនមកសោះ ព្រោះភូមិនេះមានការរស់នៅរបៀបបុរាណ ។ ម្ល៉ោះហើយវាស្តាប់អាសំឡី ដោយស្ងើចសរសើរក្រៃលែង ។ អាសំឡីបានគូរគ្រឿងម៉ាស៊ីនទាំងឡាយដែលអាចជួយកម្លាំងជាច្រើន ក្នុងកិច្ចការធ្វើស្រែចំការ ហើយអាចឱ្យមានពេលទំនេរសំរាប់រៀនអាន និងពិភាក្សាលើបញ្ហាផ្សេងៗ ។

ប៉ុន្មានអាទិត្យក្រោយមក គំរោងការរហាត់ខ្យល់របស់អាសំឡីក៏បានសម្រេច ។ គំរោងការទាំងអស់នោះ កើតចេញពីគំនិតដែលអាសំឡី ស្រង់ពីសៀវភៅបីក្បាលរបស់ពូស្និត ។ គឺសៀវភៅស្តីអំពី "ប្រដាប់ប្រដាទាំងឡាយដែលយើងអាចធ្វើបាន" "វិធីរៀបឥដ្ឋ" និង "អគ្គិសនីសម្រាប់ជនសាមញ្ញ" ។ អាសំឡីធ្វើការសិក្សានៅក្នុងរោងភ្ញាស់ពងមាន់របស់ពូស្និត ព្រោះនៅកន្លែងនោះមានតុសំរាប់គូរ ។ វាសម្ងំនៅទីនោះជាច្រើនម៉ោង លុះត្រាតែគូរប្លង់រួច ។ គេឃើញវាយកថ្មមួយដុំសង្កត់ទំព័រសៀវភៅ រួចគូរប្លង់នឹងដីសរដែលវាតៀបនឹងម្រាមជើង ។ វាគូរបណ្តើរបញ្ចេញវាចាបណ្តើរ ដោយសេចក្តីរីករាយនិងទុកចិត្ត ។

បន្តិចម្ដង ៗ ប៉ុន្តែនោះក្លាយទៅជាដែករ៉ៃ កង់ពីក្រ ស្លី ដែលសត្វទាំងឡាយមើលមិនយល់ តែបានសេចក្ដីកោតសរសើរដល់ប្រាជ្ញាអាសំប៉ូលជាខ្លាំង ។ សត្វខ្លះលួចចូលទៅមើលប្លង់អាសំប៉ូល ស្ទើរតែរាល់ថ្ងៃ ។ មាន់ ទា ក៏លួចមើលដែរ តែបែរជាខឹងនឹងខ្លួនឯង ដោយមើលមិនយល់ទាល់តែសោះ ។ មានតែអាឈ្មុះទេ ដែលមិនដែលមករវីរវល់នឹងគេ ។ វាប្រឆាំងនឹងគំរោងការរហាត់ខ្យល់នេះតាំងពីដើមទីមកម៉្លេះ ។ ថ្ងៃមួយ វាចូលមកដោយចៃដន្យ ដើរចុះដើរឡើងជុំវិញគំនូរសំប៉ូលមើលក្រដាសប្លង់ ដោយគុញទ្រទាក់ រួចហើយធ្វើជាកណ្ដាស់ដាក់ពីរបីដង ។ ដោយសេចក្ដីឈ្នានីស វាលើកជើងក្រោយ រួចនោមប្រោះលើក្រដាសនោះ ហើយដើរចេញមកក្រៅដោយឥតចេញសំដីអ្វីឡើយ ។

សត្វទាំងឡាយបែកចេញជាពីរក្រុមខុសគ្នាដោយសារតែគំរោងរហាត់ខ្យល់នេះ ។ អាសំប៉ូលបានអះអាងថា គំរោងការនេះលំបាកនឹងសំរេចណាស់ : គេត្រូវការថ្មជាច្រើនដុំសំរាប់ធ្វើជញ្ជាំង ផងក្ដារធំ ៗ ខ្សែលួស និងឌីណាម៉ូ ។ អាសំប៉ូលមិនទាន់ដឹងថា តើវាអាចរកគ្រឿងសម្ភារៈទាំងនេះបានពីណាទេ តែវាគ្រាន់តែដឹងថា វាអាចបញ្ចប់គំរោងការនេះក្នុងរវាងមួយឆ្នាំ ។ ដល់គំរោងការនេះសំរេច សត្វទាំងឡាយ



មុខជាបានធូរកម្លាំង ហើយត្រូវធ្វើការតែបីថ្ងៃក្នុងមួយអាទិត្យទេ ។ អាឈ្មុះនោះតែប្រឆាំងនឹងកិច្ចការដែលគេប្រុងធ្វើនេះ ហើយវាអះអាងថា ពេលនេះ ត្រូវតែនាំគ្នាបង្កើនផលិតផលវិញ ។ បើសត្វទាំងអស់រវល់តែគិតពីរឿងរហាត់ខ្យល់នេះបន្តិចទៀត មុខជាត្រូវអត់ចំណីស៊ីមិនខាន ។ សត្វទាំងអស់ត្រូវបែកចេញជាពីរបក្សផ្សេងគ្នា ។ ម្ខាង "បោះឆ្នោតយល់ព្រម" យកគំរោងការអាសំប៉ូល ហើយធ្វើការតែបីថ្ងៃក្នុងមួយសប្ដាហ៍ "ហើយម្ខាងទៀត" បោះឆ្នោតយល់ស្របតាមគំនិតរបស់អាឈ្មុះ ដើម្បីបានផលិតផលបរិបូណ៌ ។

មានតែអាភ្លីមួយទេ ដែលមិនចូលគណៈបក្សខាងណា ព្រោះវាមិនជឿថា ចំណីនឹងបានសម្បូណ៌ហូរហៀរ ហើយរហាត់ខ្យល់អាចជួយសម្រាលកម្លាំងឡើយ ។ ទោះជាមានឬអត់រហាត់ខ្យល់ក៏ដោយ ក៏ការរស់នៅមុខជាឋិតនៅក្នុងភាពខ្វះខាតនិងវេទនាដដែល ។

ក្រៅពីជម្លោះអំពីគំរោងការរហាត់ខ្យល់ មានបញ្ហាមួយទៀតកើតឡើង គឺកិច្ចការពារភូមិ ។ សត្វទាំងអស់យល់ថា ថ្វីបើបានជ័យជំនះម្ដងទៅលើមនុស្សហើយក៏ដោយ ក៏វាជឿថា មនុស្សនឹងវិលមកវិញដែរ ដើម្បីជួយពូស្មិត ។ ហើយតាមការពិត ពូស្មិតនិងគូកនគាត់មុខជានឹងត្រឡប់មកម្ដងទៀត

ដើម្បីសងសឹក ព្រោះដំណើរនៃបរាជ័យរបស់ពួកគាត់បានឮ សុះសាយពេញស្រុក ។ រីឯសត្វទាំងឡាយសោតក៏បញ្ចេញអាកប្បកិរិយាកាន់តែរឹងត្អឹងឡើង ។ ក្នុងរឿងការពារភូមិនេះទៀត អាសំឡីនិងអាឈ្មោះក៏ខ្វែងគំនិតគ្នាដែរ ។ ចំពោះអាឈ្មោះ សត្វទាំងអស់ត្រូវរកកាំភ្លើងមកហាត់បាញ់ឱ្យបានស្ទាត់ ។ ចំណែកអាសំឡីវិញ វាមានគំនិតថា ត្រូវតែបញ្ជូនបក្សព្រាប ឱ្យកាន់តែច្រើនឡើងដើម្បីទៅបំបះបំបោរសត្វទាំងឡាយនៅក្នុងភូមិផ្សេងទៀត ។ សត្វខ្លះជឿថា បើការពារខ្លួនឯងមិនបានត្រឹមត្រូវទេ សត្រូវមុខតែឈ្នះ ។ រីឯសត្វខ្លះទៀតមានជំនឿថា បើមានចលាចលនៅកន្លែងផ្សេងទៀត វាទាំងអស់មិនចាំបាច់រវល់នឹងការពារខ្លួនឡើយ ។ ក្រោយពីបានស្តាប់ការពន្យល់ទាំងពីរខាងមក សត្វទាំងឡាយមិនដឹងថា ខាងណាត្រូវ ខាងណាខុសទេ ។ វាហាក់ដូចជាជឿទាំងអស់ ឱ្យតែក្រុមណាពន្យល់ ។

នៅទីបំផុត ប្លង់សង់រហាត់ខ្យល់របស់អាសំឡីបានចប់សព្វគ្រប់ ។ នៅបីទីងអាទិត្យក្រោយ បញ្ហាចាប់ផ្តើមសង់រហាត់ខ្យល់នឹងត្រូវដាក់ឱ្យអង្គប្រជុំសំរេច ។ លុះសមាជិកចូលមកកាន់ជង្រុកគ្រប់គ្នាហើយ អាសំឡីក៏ក្រោកឈរឡើងដើម្បីថ្លែងអំពីផលប្រយោជន៍នៃរហាត់ខ្យល់ ទោះបីមានការ



រំខានពីហ្វូងពពែក៏ដោយ ។ បន្ទាប់មក អាឈ្មោះក្រោកឡើងប្រឆាំង ។ វាថារហាត់ខ្យល់ជាគំរោងការឥតប្រយោជន៍ ហើយស្នើឱ្យអង្គប្រជុំកុំអនុម័ត ។ វានិយាយតែមួយភ្លែត ដោយឥតរវីរវល់នឹងអ្នកដទៃ ហើយក៏ដាក់ខ្លួនអង្គុយចុះ ។ អាសំឡីក្រោកឡើង ស្រែកកំហែងពួកពពែដែលចេះតែបញ្ចេញសម្លេងរ៉ូអរ ហើយចាប់ផ្តើមអំពាវនាវដល់សុភវិនិច្ឆ័យនៃសត្វទាំងអស់ ។ អង្គប្រជុំបែកបក្សជាពីរ ។ ជូនកាលសំដីរបស់អាសំឡីធ្វើឱ្យគេធុញទ្រាន់ ។ វាឃោសនាពណ៌នាអំពីទិដ្ឋភាពភូមិសម្រែង ក្នុងពេលដែលសត្វទាំងអស់មិនចាំបាច់ធ្វើការ ។ វារៀបរាប់ពីម៉ាស៊ីនកាត់ស្មៅ ម៉ាស៊ីនចិតបន្លែ ពីផលប្រយោជន៍នៃអគ្គិសនី ដែលអាចបង្កើតម៉ាស៊ីនប្រឡេះពោត ភ្ជួរ រាស់ កិន ច្រូត ចង ក្រៅពីផ្តល់ពន្លឺគ្រប់ក្រោល ទឹកក្តៅ ត្រជាក់ និងកំដៅ ។ ក្រោយពីបានឃោសនាយ៉ាងនេះរួច អាសំឡីអាចទាយបានថា អង្គប្រជុំនឹងបោះឆ្នោតផ្តៀងទៅខាងណា ៗ ។ តែក្នុងពេលជាមួយគ្នានេះ អាឈ្មោះក្រោកឡើង ភ្នែកសំឡក់យ៉ាងខ្ញាន់ខ្ញាញ់ទៅអាសំឡី ហើយស្រែកសំឡុតអាសំឡី ដោយសម្លេងយ៉ាងខ្លាំង ដែលសត្វទាំងអស់មិនដែលឃើញវាធ្វើដូច្នេះឡើយពីកាលណាមក ។

មានសម្លេងព្រួសរមៀលឮកនៅខាងក្រៅ ហើយនៅក្នុងពេលនោះ គេឃើញឆ្កែធំៗចំនួនប្រាំបួន ដែលពាក់ប្រឡៅស្ពាន់ពាក់នៅក ដើរចូលមកក្នុងជង្រុក ។ ឆ្កែទាំងនោះរត់តំរង់ទៅរកអាសំឡី ដែលក្លាមនោះ ស្ទុះចេញពីកន្លែងដើម្បីគេចឲ្យផុតពីចង្កូមរបស់ឆ្កែ ។ អាសំឡីរត់ចេញទៅក្រៅ រំពេចនោះ ហ្វូងឆ្កែក៏រត់ទៅតាមក្រោយ ។ ដោយតក់ស្លុតនិងភ័យស្ញើរពេកនិយាយមិនរួច សត្វទាំងអស់ក៏នាំគ្នារត់ស្រមកមើលត្រឹមមាត់ទ្វារដើម្បីមើលការដេញគ្នា ។ អាសំឡីរត់កាត់ទីវាលស្មៅទៅរកផ្លូវធំ ។ វារត់លឿនដូចជាជ្រូកឯទៀតដែរ រីឯឆ្កែក៏ដេញប្រកិតជិតជើងវា ។ ជាអកុសល អាសំឡីភ្លាត់ជើងដួល ឆ្កែជិតទៅដល់ អាសំឡីស្ទុះក្រោកឡើងហើយរត់ទៅទៀត ។ ឆ្កែក៏ដេញតាមទៀត ។ អាឆ្កែមួយនោះជិតត្រូវខាំកន្ទុយអាសំឡីបានទៅហើយ តែវាបានគ្រវាត់កន្ទុយនោះផុតទាន់ពេលវេលា ។ អាសំឡីខំប្រឹងប្រវែងប្រមូលកម្លាំងទាំងអស់ដែលនៅសល់ទាំងប៉ុន្មាន ហើយរត់ពោះពួយខ្លួនវាចូលទៅក្នុងរន្ធមួយ ។ ចាប់ពីពេលនោះមក អាសំឡី ក៏បាត់ខ្លួនក្នុងប្រហោងនោះឯង ។

សត្វទាំងឡាយ ក៏ដើរចូលក្នុងជង្រុកវិញដោយស្ងាត់ស្ងៀមនិងដោយភ័យរន្ធត់ ។ ក្នុងពេលនោះ ឆ្កែក៏ត្រឡប់



មកវិញដែរ ។ ដើមឡើយ សត្វណាក៏ឆ្ងល់ថា តើឆ្កែទាំងនោះវាមកពីណា ។ តែអាថ៌កំបាំងនេះ ត្រូវបានទទួលសេចក្តីបំភ្លឺភ្លាម ៖ ឆ្កែនេះជាកូនឆ្កែដែលអាឈ្មុះវាយកទៅចិញ្ចឹមទុកដោយលួចលាក់ ។ ថ្វីបើវានៅក្មេងក៏ដោយ ក៏វាប្រកបទៅដោយរាងធាត់ធំ កាចសាហាវដូចឆ្កែចចកដែរ ។ អាឈ្មុះថែទាំវាដោយយកចិត្តទុកដាក់ និងស្និទ្ធស្នាល ម៉្លោះហើយវាតែងបក់កន្ទុយទៅរកអាឈ្មុះ ដូចឆ្កែទាំងឡាយដែលធ្លាប់ស្រឡាញ់ចៅហ្វាយវាដូច្នោះដែរ ។

ដោយមានឆ្កែនៅពីក្រោយខ្នង អាឈ្មុះបានឡើងលើវេទិកាដែលអាសំឡីតែងប្រើសម្រាប់ធ្វើសន្ទរកថា ហើយប្រកាសថាចាប់តាំងពីអាទិត្យនេះតទៅ មីទីងត្រូវបញ្ឈប់លែងឲ្យមាន ។ វាថាមីទីងគ្មានប្រយោជន៍អ្វីឡើយ ហើយនាំឲ្យខាតពេលវេលា ។

ចាប់ពីថ្ងៃនោះមក កិច្ចការក្នុងភូមិទាំងអម្បាលមាណត្រូវដាក់ឲ្យគណៈពិសេសមួយពិនិត្យនិងសម្រេច ។ គណៈកម្មការនេះមានជ្រូកជាសមាជិក និងអាឈ្មុះជាប្រធាន ។ ការប្រជុំនឹងត្រូវធ្វើឡើងជាសម្ងាត់ ហើយសេចក្តីសំរេចនឹងផ្សាយឲ្យសត្វទាំងឡាយដឹងនៅពេលក្រោយ ។ ក៏ប៉ុន្តែសត្វទាំងអស់ត្រូវមកគោរពទង់រាល់ព្រឹកថ្ងៃអាទិត្យ ហើយច្រៀងបទ

"បដិវត្តន៍" ។ បន្ទាប់មកសត្វនិមួយៗ ត្រូវទទួលរបបញ្ញា
សម្រាប់អាទិត្យក្រោយ ។ ការជជែកនឹងឈប់ឲ្យមានចាប់
ពីពេលនេះតទៅ ។

បន្ទាប់ពីបានទទួលការភិតភ័យ ដែលបណ្ដាលមកពីឧប្ប-
ត្តិហេតុថ្មីៗនេះមក សត្វទាំងឡាយស្ដាប់បញ្ជាទាំងនេះ
ដោយស្រឡាំងកាំង ។ ភាគច្រើនចង់ប្រឆាំងនឹងនយោបាយ
ថ្មីនេះ តែរកលេសមិនបាន ។ អាព្រូញកើតទុក្ខ ពិបាកចិត្ត
ត្រចៀកវាធ្លាក់ គ្រវីក្បាលជាច្រើនដង ហើយខំប្រឹងគិតឥត
ចេញស្អីសោះឡើយ ។ ចំណែកជ្រូកហាក់ដូចជាមានយោបល់
ច្រើន ។ កូនជ្រូកបួនដែលអង្គុយជួរមុខក្រោកឡើងដើម្បីផ្ដើម
បញ្ចេញបតិប្រឆាំង ។ ប៉ុន្តែឆ្កែដែលនៅពីក្រោយអាឈ្មោះ
ក្រហឹមសំឡុត ម៉្លោះហើយជ្រូកទាំងបួនក៏ដាក់ខ្លួនអង្គុយ
វិញដោយឥតចេញស្ដី ។ បន្ទាប់មកហ្វូងពពែក៏ចាប់បន្លឺ
សម្លេងឡើង : "ជើងបួនល្អ ជើងពីរអាក្រក់" បន្តបន្ទាប់គ្នា
ប្រហែលជិតកន្លះម៉ោង ជាហេតុធ្វើឲ្យការជជែកប្រព្រឹត្តទៅ
លែងកើត ។

នៅថ្ងៃបន្ទាប់ អាប្រាផូកានត្រូវគេប្រើឲ្យដើរពន្យល់
នយោបាយថ្មីនេះឲ្យសត្វទាំងអស់បានជ្រួតជ្រាប ។ "សម
មិត្ត" វាពោលឡើងអញ្ជើញដាក់ថា ឯងទាំងអស់មាន



សេចក្ដីគោរពដល់ពលិកម្មនៃមិត្តឈ្មោះ ដែលបានធ្វើការថែម
សំរៃកម្លាំង ។ ចូរឯងកុំប្រញ្ញាំឲ្យសោះថាភារៈកិច្ចនៃអ្នកដឹក
នាំជាការសប្បាយ ។ ផ្ទុយទៅវិញ វាជាបន្ទុកធ្ងន់ណាស់
ក្នុងការទទួលខុសត្រូវ ។ គ្មាននរណាម្នាក់ឡើយ ដែល
មានជំនឿជាងមិត្តឈ្មោះ អំពីហេតុដែលថាសត្វទាំងឡាយមាន
សិទ្ធិស្មើគ្នាទេ ។ គាត់សប្បាយចិត្តទៅវិញទេ បើសិនជា
ដឹងថាឯងទាំងអស់គ្នាចេះគិតដោយខ្លួនឯង ។ ក៏ប៉ុន្តែជួន
កាលឯងគិតខុស ហើយដល់ពេលហ្នឹង តើឯងសម្រេចឲ្យ
អ្នកណាជួយ ? ឧបមាថា បើឯងសម្រេចចិត្តថាតាមអាសំឡី
វិញ ដោយឯងស្ដាយអាគំរោងការណ៍របាត់ខ្យល់របស់វា
នោះ — តែបើតាមរបៀបគិតអញថាឯងខុសហើយ ព្រោះដូច
ឯងដឹងស្រាប់ អាសំឡីអាចចាត់ទុកជាសត្វឧក្រិដ្ឋមួយ ។
មកដល់ត្រង់នេះ ជ្រូកស្រែកគាត់ឡើងថា : "វាបានតស៊ូ
យ៉ាងអង់អាចជាមួយយើងក្នុងពេលប្រយុទ្ធ" ។

"មានសេចក្ដីក្លាហានមិនទាន់គ្រប់គ្រាន់ទេ — អាប្រាផូ
តបវិញភ្លាម — សេចក្ដីស្មោះត្រង់និងការស្ដាប់បង្គាប់វាសំខាន់
ជាង ។ ហើយបើនិយាយពីរឿងប្រយុទ្ធនោះ អញជឿថា
បន្តិចទៀតគេនឹងដឹងច្បាស់ថាពលិកម្មរបស់អាសំឡី វាពុំមាន
តំឡៃប៉ុន្មានទេ ។ វិន័យ សមមិត្ត ! វិន័យទាហានដែលរឹង

ដូចដែក ! ហ្នឹងគឺជាបញ្ហារបស់យើងសព្វថ្ងៃ ! ។ ក្រុបខ្លួនបន្តិច សត្រូវមុខជាជាន់ក្បាលយើង ។ តើវង្វេងទាំងអស់គ្នាចង់ឲ្យអាស្វិតត្រឡប់មកវិញឬអី ?" ។

នៅពេលនេះទៀត គ្មានសត្វណាមួយអាចឆ្លើយឆ្លងសំដីបានឡើយ ។ តាមពិតទៅ សត្វទាំងអស់មិនចង់ឲ្យពូស្វិតត្រឡប់មកវិញទេ ។ ហើយបើឃើញថា ការជជែកគ្នានៅរាល់ព្រឹកថ្ងៃអាទិត្យអាចបណ្ដាលឲ្យពូស្វិតត្រឡប់មកវិញ ពួកគេយល់ថា គួរបញ្ឈប់ការជជែកគ្នានោះលែងឲ្យមានទៅ ។ អាព្រូញដែលបានប្រើពេលគិតជាច្រើននោះ ក៏ឆ្លើយតបវិញភ្លាមថា : " ឲ្យតែមិត្តឈ្មោះធ្វើអ្វីហើយ វាតោងតែត្រូវ" ។ ហើយចាប់ពីថ្ងៃនោះមក អាព្រូញចាំទុកជានិច្ចថា : "អាឈ្មោះនិយាយត្រូវទាំងអស់" បន្ថែមលើពាក្យបំណាំរបស់វាមួយទៀតគឺ " អញត្រូវធ្វើការឲ្យកាន់តែច្រើន" ។

ពេលនេះ ធាតុអាកាសល្អ ការភ្ជួររាស់ក៏ចាប់ផ្ដើម ។ បន្ទប់ដែលអាសំឡីយកសំរាប់គូរប្លង់រហាត់ខ្យល់នោះត្រូវបិទទ្វារចោល ដោយគេត្រូវបំភ្លេចប្លង់នោះចោលសិន ។ តាមនយោបាយថ្មី រាល់ព្រឹកថ្ងៃអាទិត្យ ប្រហែលម៉ោង១០ សត្វទាំងអស់មកជួបជុំគ្នាក្នុងជង្រុក ដើម្បីទទួលបញ្ជាសម្រាប់អាទិត្យក្រោយ ។ សត្វទាំងឡាយបាននាំគ្នាគាស់យកខ្មោច



អា "គំនិត" ចេញពីផ្នូរ ហើយយកក្បាលខ្មោចទៅសំអាតដើម្បីយកបកតាំងលើគល់ឈើទន្ទឹមនឹងកាំភ្លើងក្បែរដងទង់ ។ នៅពេលហូតទង់រួចហើយ សត្វទាំងអស់ត្រូវដើរមកឈរនៅមុខក្បាលខ្មោចអាគំនិតរួចធ្វើគារវៈកិច្ច មុននឹងដើរចូលជង្រុក ។ ឥឡូវវាទាំងអស់គ្នាឈប់អង្គុយជាមួយគ្នាដូចកាលពីជំនាន់មុនទៀតហើយ ។ អាឈ្មោះ អាព្រាជ្ញ និងជ្រូកមួយទៀតឈ្មោះអា "គវី" ដែលល្បីល្បាញខាងសរសេរចម្រៀង និងកំណាព្យ អង្គុយនៅលើវេទិកា ឆ្កែទាំងប្រាំបួនអង្គុយសងខាងអាទាំងបី ធ្វើជារបាំង ។

នៅខាងក្រោយគឺជាកន្លែងពួកជ្រូក ។ ក្រៅពីនោះ សត្វទាំងអស់អង្គុយបែរមុខទៅរកវេទិកា ។ អាឈ្មោះអានបញ្ជាសំរាប់អាទិត្យក្រោយដោយសំដីម៉ាត់ ៗ ដូចទាហាន ។ បន្ទាប់ពីនោះ សត្វទាំងអស់ច្រៀងបទ " បដិវត្តន៍" ។ រួចហើយទើបបិទសម័យប្រជុំ ។

បីអាទិត្យបានកន្លងផុតទៅហើយ បើគិតពីពេលដែលគេបានបណ្ដេញអាសំឡីចេញពីភូមិមក ។ សត្វទាំងឡាយហាក់ដូចជាមីងមាំងក្នុងចិត្ត ក្នុងពេលដែលបានដឹងថា រហាត់ខ្យល់របស់អាសំឡីត្រូវគេរៀបចំសង់ឡើងវិញ ។

អាឈ្មោះឥតបានឲ្យយោបល់អ្វីឡើយក្នុងការកែប្រែនេះ ។

តែវាបានប្រាប់ឮសឹងមុខថាគំរោងការនេះ ត្រូវការចំណាយកម្លាំងនិងពេលច្រើន ហើយថែមទាំងអាចតម្រូវឲ្យបន្ថយចំណីផង បើសិនជាមានការចាំបាច់ ។ ប្លង់និងកិច្ចការត្រូវរៀបចំយ៉ាងល្អិតល្អន់ ។ គណៈកម្មការដែលមានសមាជិកសុទ្ធតែជ្រូកនោះបានគិតការនេះជាងបីអាទិត្យមកហើយ ។ បើគិតដល់ការកែប្រែខ្លះៗផង រោហាត់ខ្យល់នេះអាចធ្វើហើយក្នុងរយៈពេលពីរឆ្នាំ ។

យប់នោះអាប្រាជ្ញបានពន្យល់ដល់សត្វទាំងឡាយថាតាមពិតទៅអាណ្ណុះមិនដែលប្រឆាំងនឹងគំរោងការរោហាត់ខ្យល់នេះទេ ។ ផ្ទុយទៅវិញគឺអាណ្ណុះនេះហើយដែលជាអ្នកផ្ដើមគំនិតមុនគេតាំងពីដើមទីមកម្ល៉េះ ។ ហើយប្លង់ដែលអាសំឡីបានយកមកបង្ហាញគេឯងនោះគឺបានចម្លងចេញពីឯកសារជាច្រើនដែលអាសំឡីបានលួចពីអាណ្ណុះ ។ ដូច្នេះរោហាត់ខ្យល់ទៅជាគំនិតផ្ទាល់របស់អាណ្ណុះទៅវិញ ។ ក៏ប៉ុន្តែបើមានអ្នកណាមួយសួរថាហេតុដូចម្ដេច បានជាអាណ្ណុះត្រឡប់ទៅជាប្រឆាំងនឹងគំរោងការនេះទៅវិញ អាប្រាជ្ញបាត់មាត់ឈឹង ។ វាបែរជាឆ្លើយទៅវិញថានេះជាឧបាយកលរបស់អាណ្ណុះទេ ។ អាណ្ណុះប្រឆាំងនឹងអាសំឡី មិនមែនមកពីរឿងរោហាត់ខ្យល់ទេ គឺមកពីវាចង់បណ្ដេញអាសំឡីចោលដោយសារអានេះ មាន



គំនិត និងអានុភាពអាក្រក់ដែលអាចទៅជាគ្រោះថ្នាក់ដល់សត្វទាំងអស់ ។ ឥឡូវអាសំឡីបាត់ទៅហើយ ដូច្នេះគំរោងការនេះអាចបន្តទៅទៀតដោយគ្មានការជ្រៀតជ្រែករបស់វាទេ ។ អាប្រាជ្ញខំអធិប្បាយប្រាប់សត្វទាំងអស់ថា រឿងទាំងនេះគេហៅថាកលយុទ្ធ ឬស្នៀតនយោបាយ ។ វាទន្ទេញពាក្យនេះជាច្រើនដង : "កលយុទ្ធ ! អាសម្លាញ់ កលយុទ្ធ" ។ និយាយបណ្ដើរ ដើរចុះដើរឡើងបណ្ដើរ បក់កន្ទុយចុះឡើងព្រមទាំងបញ្ចេញសំណើចផង។ សត្វទាំងអស់គ្មានយល់សោះចំពោះពាក្យ "កលយុទ្ធ" ។ តែដោយនៅពេលអាប្រាជ្ញនិយាយម្ដងៗ អាឆ្កែទាំងប្រាំបួនចេះតែគ្រហឹមដាក់ សត្វទាំងឡាយក៏ត្រូវបង្ខំចិត្តទទួលសេចក្ដីពន្យល់នេះដោយឥតប្រកែកមួយម៉ាត់ឡើយ ។

# ជំពូក ៦

មួយឆ្នាំកន្លងផុតទៅ សត្វទាំងអស់ធ្វើការដូចខ្ញុំគេ ។ ក៏ប៉ុន្តែវាហាក់ដូចជាសប្បាយនិងកិច្ចការទាំងនោះ ។ វាគ្មានដែលត្អូញអំពីរឿងអស់កម្លាំងនិងអំពីពលិកម្មដែលវាបានបំពេញមួយសោះ ព្រោះវាយល់ច្បាស់ថាអ្វីៗ ដែលវាធ្វើនេះ គឺសំរាប់វានិងបិត្តុវាជំនាន់ក្រោយ មិនមែនសំរាប់អាមនុស្សកំជិលនិងរមេចោរមួយក្រុមនោះទេ ។

គ្រប់រដូវ ពួកសត្វត្រូវគេបង្ខំឲ្យធ្វើការ ៦០ ម៉ោងក្នុងមួយអាទិត្យ ហើយចាប់ពីខែសីហាមកគេត្រូវធ្វើការរាល់រសៀលថ្ងៃអាទិត្យទៀតផង ។ អាណាប៉ុះបានអះអាងថាធ្វើការពេលរសៀលថ្ងៃអាទិត្យនេះ គឺធ្វើដោយស្ម័គ្រចិត្ត ក៏ប៉ុន្តែ បើអ្នកណាម្នាក់មិនទៅធ្វើការ អ្នកនោះនឹងបានទទួលចំណីតែពាក់កណ្តាលទេ ។ ថ្វីបើពួកសត្វធ្វើការយ៉ាងនេះក៏ដោយ ក៏មានកិច្ចការជាច្រើននៅសល់ ធ្វើមិនហើយដែរ ។ ដូចជាការច្រូតកាត់ ឆ្នាំនេះមិនសូវបានផលទេ ។ ចំការដែលពីដើមធ្លាប់មានដំណាំ ឥឡូវត្រូវទុកចោលទំនេរទៅវិញ ព្រោះពុំបានត្រូវភ្ជួររាស់ទាន់ពេលវេលា ។ ស្ថានការណ៍បែបនេះ



បណ្តាលឲ្យមានឧបសគ្គជាច្រើនទៅអនាគត ។ ការសង់រហាត់ខ្យល់ចោទបញ្ហាជាច្រើន ។ នៅក្នុងភូមិមានថ្ម ខ្សាច់ និងស៊ីម៉ង់ ដែលនៅសល់ ម៉្លោះហើយសម្ភារៈសំណង់អាចមានគ្រប់គ្រាន់ ។ តែបញ្ហាមួយដែលត្រូវតែដោះស្រាយភ្លាម គឺការបំបែកថ្មឲ្យតូចល្មមតាមទំហំកំរិត ។ ដូចជាគ្មានវិធីណាក្រៅពីប្រើចបត្រសេះ ដងសន្ទូចទេ ក៏ប៉ុន្តែគ្មានសត្វណាចេះប្រើប្រដាប់ទាំងនោះសោះ ។ នេះមកពីសត្វទាំងនោះមិនអាចឈរលើជើងពីរបានយូរ ។ ក្រោយពីបានប្រើកម្លាំងឥតប្រយោជន៍ អស់ច្រើនអាទិត្យមក ទើបមានគំនិតមួយលេចឡើង គឺគេត្រូវប្រើកម្លាំងទម្ងន់ ។ ថ្មធំៗដែលប្រើមិនកើត ត្រូវកំទេចឲ្យតូចៗសិន មុននឹងយកទៅប្រើប្រាស់ ។ ម៉្លោះហើយសត្វទាំងឡាយយកខ្សែពួរចងជុំវិញដុំថ្មធំៗនោះ រួចហើយ គោ សេះ ពពែ និងសត្វទាំងអស់ដែលចេះទាញខ្សែ (សូម្បីតែជ្រូក ក៏ចូលរួមក្នុងសកម្មភាពនេះដែរ) ក៏ត្រូវកេណ្ឌឲ្យមកជួយទាញដុំថ្មឡើងទៅលើទួលរួចហើយទម្លាក់ចុះមកក្រោមឲ្យបែកខ្ទេចខ្ទីជាដុំតូចៗ ។ ការដឹកជញ្ជូនដុំថ្មតូចនេះប្រព្រឹត្តទៅបានដោយស្រួល ។ សេះអូសរទេះផ្ទុកពេញដោយដុំថ្ម ពពែអូសថ្មមួយដុំ ចំណែកមីក្អុក និងអាភ្លើ ក៏ចូលរួមក្នុងការដញ្ជូននេះយ៉ាងសកម្ម ។

ដល់ក្នុងរដូវប្រាំង សត្វក៏បានជញ្ជូនថ្មជាច្រើនដុំមកទុកជាគំនរ ។ គេក៏ចាប់ផ្ដើមលើកជញ្ជាំងក្រោយការដឹកនាំនៃជ្រូក ។

ប៉ុន្តែដំណើរការណ៍បានប្រព្រឹត្តទៅយ៉ាងលំបាក និងអស់ពេលជាច្រើន ។ ជួនកាលវាត្រូវប្រើពេលពេញមួយថ្ងៃ ដើម្បីទាញថ្មមួយដុំឡើងដល់កំពូលទួល ។ ហើយជួនកាល ដល់ពេលទម្លាក់ថ្មចុះមកក្រោម ថ្មក៏មិនបែកទៀត ។ គ្មានកិច្ចការណាមួយដែលធ្វើឡើងកើត ដោយឥតជំនួយពីអាព្រូញទេ ព្រោះកម្លាំងវាម្នាក់ឯងស្មើនិងកម្លាំងសត្វទាំងអស់រួមគ្នា ។ ពេលដែលដុំថ្មក្រឡាប់ម្ដង ៗ សត្វទាំងអស់ស្រែកញៀវញ៉ាវ ដោយអស់សង្ឃឹម ព្រោះទម្ងន់ថ្មប្រទាញវាទាំងអស់ចុះក្រោម ។ ពេលនោះមានតែអាព្រូញទេ ដែលអាចធ្វើឲ្យដុំថ្មដែលកំពុងរមៀលចុះក្រោមនៅនឹងមួយកន្លែងបាន ។ វាអូសថ្មរំកិលឡើងលើបន្តិចម្ដង ៗ ដកខ្យល់ឃ្លូរ ៗ ក្រចកជើងទាំងបួនក្រាញជាប់ក្នុងដី បែកញើសស្រោកពេញទាំងខ្លួន ។ នៅពេលដែលបានឃើញវាធ្វើការដូច្នេះ សត្វទាំងអស់ក៏អត់ទ្រាំសរសើរវាមិនបាន ។ មីកណ្ដូបសេះ តែងតែដាស់តឿនវាថាកុំឲ្យធ្វើការហួសកម្លាំងពេក តែអាព្រូញមិនដែលស្ដាប់ពាក្យទូន្មាននរណាទាំងអស់



ព្រោះវានៅចាំពាក្យគ្នាត់ឃើក ៖ “ អញត្រូវធ្វើការឲ្យកាន់តែច្រើន ” និងពាក្យ “ មិត្តណាប៉ុះ ធ្វើត្រូវទាំងអស់ ” ។ ពាក្យដាស់សតិទាំងនេះ ប្រៀបបាននឹងថ្នាំប៉ូវដែលជួយវាឲ្យដោះស្រាយបញ្ហាទាំងអស់ ។ វាបានអង្វរសុំមាន់ឲ្យរងាវដាស់វាកន្លះម៉ោង មុនពេលក្រោកធ្វើការ ។ ហើយឲ្យតែមានពេលទំនេរ វាតែងទៅកាន់កន្លែងបំបែកថ្ម ដើម្បីអូសថ្មដែលបំបែកហើយ យកមកទុកនៅកន្លែងសង់រហាត់ខ្យល់ ដោយឥតមានត្រូវការជំនួយពីអ្នកណាឡើយ ។

សត្វទាំងអស់ ហាក់ដូចជាមិនទាន់ធុញទ្រាន់នឹងកិច្ចការនៅឡើយទេ ទោះបីវាបានខិតខំយ៉ាងលំបាកអស់មួយរដូវហើយក៏ដោយ ។ ថ្វីបើវាបានទទួលចំណីមិនច្រើនជាងពីកាលសម័យពូស្វិតក៏ដោយ ក៏ម្ហូបចំណីទាំងនោះមិនតិចជាងមុនដែរ ។ ការខុសគ្នាពីសម័យមុនគឺនៅត្រង់ថា នៅពេលឥឡូវនេះពួកគេរកចំណីសម្រាប់តែពួកគេ មិនមែនសម្រាប់មនុស្ស ៤ - ៥ នាក់ទៀតទេ ។ គ្រាន់តែប៉ុណ្ណេះ វាសប្បាយចិត្តណាស់ទៅហើយ ។ ម្យ៉ាងទៀតរបៀបធ្វើការថ្មី ក៏ដូចជាមានប្រសិទ្ធិភាពជាងមុន ហើយកម្លាំងក៏មិនបានត្រូវចំណាយចោលទទេ ៗ ដែរ ។ ដូចជាការចោចស្មៅ សត្វធ្វើបានល្អ ហើយស្អាតជាងមនុស្សទៅទៀត ។ ឥឡូវដោយគ្មានសត្វ

ណាហ៊ានលួច របងការពារចំការដែលមានដំណាំ មិនចាំបាច់ជាត្រូវធ្វើទេ ហើយការថែទាំរបងនិងទ្វារសោតក៏ឥតមានដែរ ។

តែទោះជាយ៉ាងដូចនោះក៏ដោយ ក៏ដល់ចុងរដូវប្រាំងនេះ ឃើញថាមានកិច្ចការច្រើនដែលមិនទាន់បានបំពេញ ។ ប្រេងដែកគោល - ខ្សែ - ចំណីឆ្កែ - ក្រចកសេះ ជាវត្ថុត្រូវការជាចាំបាច់ហើយមិនអាចធ្វើកើតនៅក្នុងភូមិ ។ គ្រាប់ពូជ - ជីប្រដាប់ប្រដារផ្សេង ៗ និងគ្រឿងចក្រសម្រាប់រហាត់ខ្យល់នៅខ្វះខាតច្រើន ។ តើត្រូវធ្វើយ៉ាងណាឲ្យបានរបស់ទាំងនេះ? ។ មិនទាន់មានសត្វណាមួយដែលអាចផ្ដល់យោបល់អំពីរឿងនេះបានឡើយ ។

ព្រឹកថ្ងៃអាទិត្យមួយ ពេលដែលសត្វទាំងអស់ជួបជុំគ្នាដើម្បីទទួលបញ្ជាពីលើ អាឈ្មុះបានប្រកាសថា វានឹងផ្លាស់យកនយោបាយថ្មី ។ ចាប់ពីពេលនេះទៅ ភូមិសម្រែងនឹងធ្វើជំនួញជាមួយភូមិជិតខាង ។

ការធ្វើជំនួញនេះ មិនមែនត្រូវធ្វើដើម្បីប្រាក់ទេ តែដើម្បីឲ្យបានប្ដូរយករបស់ដែលភូមិសម្រែងត្រូវការ ។ គំរោងការរហាត់ខ្យល់ត្រូវធ្វើមុនអ្វី ៗ ទាំងអស់ ។ រឿងនេះអាឈ្មុះបានបញ្ជាក់ហើយ បញ្ជាក់ទៀត ។ ឥឡូវនេះ វាថាបាន



និយាយលក់ចំបើងនិងស្រូវមួយចំនួន ។ តែបើនៅតែខ្វះខាតវានឹងលក់ពងមាន់ទៀត ព្រោះនៅឯផ្សារគេត្រូវការស៊ុតមាន់ណាស់ បានប៉ុន្មានគេទិញប៉ុណ្ណឹង ។ មាន់ត្រូវតែធ្វើពលិកម្ម និងវិភាគទានសម្រាប់គំរោងការរហាត់ខ្យល់នេះ ។ អាឈ្មុះបានអង្វរមាន់ ហើយសុំឲ្យយល់ចំពោះការចាំបាច់នៃវិធានការនេះ ។

សត្វទាំងអស់មានការមិនពេញចិត្តជាថ្មីម្ដងទៀត ។ ការទាក់ទងជាមួយមនុស្ស ត្រូវហាមផ្ដាច់មិនឲ្យមាន មិនត្រូវរកស៊ីជាមួយមនុស្ស មិនត្រូវយកប្រាក់មកធ្វើជាមធ្យោបាយ ។ តើនេះមិនមែនជាសេចក្ដីសំរេចចិត្ត ដែលសត្វទាំងអស់បានយល់ព្រម ក្រោយពីបានធ្វើបដិវត្តន៍បណ្ដេញពូស្មិតទេឬអ្វី? ។ គេទាំងអស់គ្នានៅចាំសេចក្ដីសំរេចចិត្តទាំងនេះ ឬយ៉ាងហោចណាស់ក៏អ្នកខ្លះមិនទាន់ភ្លេចគំនិតនេះនៅឡើយដែរ ។ កូនជ្រូកមួយដែលបានជំទាស់នឹងអាឈ្មុះ ក្នុងពេលដែលវាថានឹងបំបាត់មិនឲ្យមានមីទីងនោះបានក្រោកឈរឡើងហើយប្រកែកដោយភិតភ័យចំពោះគំនិតថ្មីរបស់អាឈ្មុះ តែទីបញ្ចប់វាត្រូវគំរាមដោយសម្លេងគ្រហឹមរបស់ឆ្កែ ។ ពពែបានជួយបន្ថែមក្រោយពីជ្រូកដែរ តែត្រូវនៅស្ងៀមបាត់មាត់ទៅវិញ ។ ទីបំផុត អាឈ្មុះលើកជើងឡើងសុំសេចក្ដីស្ងាត់ស្ងៀម

រួចហើយប្រកាសដាច់ខ្ញាំថា វាបានសំរេចការនោះអស់ទៅហើយ ។ វាមិនចង់ឲ្យសត្វណាទៅធ្វើការទាក់ទងជាមួយមនុស្សក្រៅពីវាទេ ព្រោះវាក៏ប្រឆាំងនឹងគំនិតនេះដែរ ។ វានឹងធ្វើការនេះខ្លួនវាទាំងអស់ ។ ពូ"ពាង" ដែលនៅភូមិ"គ្រពាំង"ស្ម័គ្រចិត្តធ្វើជាឈ្មួញកណ្ដាលទិញដូរពីភូមិសម្រែងទៅលក់ឯផ្សារ ហើយគាត់សន្យាថានឹងមកភូមិសម្រែងរាល់ព្រឹកថ្ងៃច័ន្ទ ដើម្បីជួបនឹងអាឈ្មុះ ។

អាឈ្មុះបញ្ចប់សន្ទរកថាវាដោយពាក្យស្លោក : "ជយោសត្វនៅភូមិសម្រែង" ហើយក្រោយពីច្រៀងបទ"បដិវត្តន៍"មក ការប្រជុំក៏ត្រូវបិទ ។

អាប្រាជ្ញ ដើរជុំវិញភូមិដើម្បីពន្យល់សត្វទាំងឡាយ អំពីនយោបាយថ្មីរបស់អាឈ្មុះ ។ វាបានរ៉ាយរ៉ាប់ថា កាលជំនាន់អាសំឡី គ្មានការសំរេចចិត្តប្រឆាំងនឹងការធ្វើជំនួញនិងគ្មានហាមមិនឲ្យសត្វប្រើប្រាស់លុយកាក់ទេ ។ វាជាការប្រឌិតរបស់អាសំឡី ដើម្បីបំភ័នមតិអង្គប្រជុំ ។ សត្វខ្លះនៅតែមានការសង្ស័យលើសំដីអាប្រាជ្ញ ។ តែអាប្រាជ្ញបានពន្យល់តទៅទៀតថា : "តើឯងនៅតែមិនជឿថា រឿងហ្នឹងជាការយល់សប្តិរបស់ឯងទេអី ? តើឯងមានអីជាភ័ស្តុតាង ដែលបង្ហាញថាមានសេចក្ដីសំរេចចិត្តនោះ ? តើវាមានសរសេរជា



ដោយហេតុអ្វីអក្សរនោះនៅក្នុងណោះ ?" ។ កាលបើបានដឹងថាគ្មានសេចក្ដីសំរេចចិត្តអ្វីទេក្នុងរឿងហ្នឹងនោះ សត្វទាំងអស់ក៏ទទួលនូវពាក្យពន្យល់របស់អាប្រាជ្ញ ហើយជឿថា ខ្លួនវាយល់ច្រឡំទាំងអស់ ។

រាល់ព្រឹកថ្ងៃចន្ទ គេឃើញពូពាងចូលមកក្នុងភូមិសម្រែងដូចពាក្យសន្យា ។ គាត់មានរាងតូច មុខមាត់មានអាថិកំបាំងដោយគាត់មានទុកពុកមាត់ស្រមេមស្រមាម ។ គាត់ធ្លាប់រកស៊ីលក់ដូរបន្តិចបន្តួច ។ គាត់ពូកែឃោសនាថាភូមិសម្រែងត្រូវតែរកស៊ីហើយត្រូវយកគាត់ជាឈ្មួញកណ្ដាល ។ សត្វទាំងឡាយលួចមើលគាត់ចេញចូលភូមិដោយសេចក្ដីភិតភ័យហើយលាក់ខ្លួនមិនហ៊ានចេញមកឲ្យគាត់ឃើញឡើយ ។

ក៏ប៉ុន្តែនៅពេល ដែលឃើញអាឈ្មុះចៅហ្វាយវា ឈរជើងពីរយ៉ាងអង់អាច និយាយកិច្ចការជាមួយ ពូពាង សត្វខ្លះក៏ហាក់ដូចជាមានការកក់ក្ដៅឡើងវិញ ក្នុងការផ្លាស់ប្ដូរនយោបាយថ្មីនេះ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ការទាក់ទងជាមួយមនុស្សមិនបានស្និទ្ធស្នាលដូចជំនាន់មុនឡើយ ។ មនុស្សមិនមែនមិនស្អប់សត្វទាំងឡាយនៅក្នុងភូមិសម្រែងនេះទេ ថ្វីបើភូមិនេះបានចំរើនលូតលាស់ជាងមុនក៏ដោយ ។ តាមពិត មនុស្សកាន់តែស្អប់ខ្ពើមសត្វនៅភូមិនេះកាន់តែខ្លាំង

ឡើង ។ នរណាក៏បានជំនឿដែរថា ភូមិសប្រែងនឹងវិនាសអន្តរាយក្នុងពេលឆាប់ៗនេះ ហើយគំរោងការរហាត់ខ្យល់នោះសោតក៏មុខតែបរាជ័យមិនខាន ។ គេឧស្សាហ៍ជួបជុំគ្នានៅមុខផ្ទះមេឃុំ ហើយជជែកគ្នាអំពីរហាត់ខ្យល់ ។ ខ្លះថាអាម៉ាស៊ីននេះមុខជានឹងរលំថ្ងៃណាមួយ ហើយបើបែរជាមិនរលំទៅវិញ មុខជានឹងមិនអាចបង្កើតផលអ្វីបានឡើយ ។ តែមនុស្សទាំងឡាយក៏ស្ងើចសរសើរសត្វក្នុងភូមិសប្រែងដែរ ព្រោះថាសត្វទាំងនោះមានគំនិតចេះគ្រប់គ្រងខ្លួនដោយខ្លួនឯង ។ អ្នកខ្លះចាប់ហៅភូមិនេះថាភូមិ "វិមានសត្វ" ទៅហើយ ។ អ្នកខ្លះអស់សង្ឃឹមលើពូស្និត ក្នុងកិច្ចដណ្តើមយកភូមិសប្រែងរបស់គាត់មកវិញ ។ ឥឡូវនេះ ពូស្និតបានទៅរស់នៅក្នុងភូមិមួយទៀតទៅហើយ ។

ក្រៅពីពូពាង ភូមិសប្រែងពុំទាន់បានធ្វើការទាក់ទងជាមួយមនុស្សណាម្នាក់ទៀតឡើយ ។ ក៏ប៉ុន្តែមានពាក្យចចាមអារាមថា 'អាឈ្មុះកំពុងធ្វើការទាក់ទងជាមួយពូថង នៃភូមិទួលក្រាំងសៀម និងពូយៀង នៃភូមិត្រពាំងស្រកី ។

ថ្ងៃនេះ ពួកជ្រូកបានផ្លាស់កន្លែងទៅនៅក្នុងផ្ទះពូស្និត ។ សត្វទាំងឡាយដូចជានៅចាំច្បាស់ថា វាទាំងអស់គ្នាបានប្រឆាំងនឹងគំនិតយកផ្ទះជាកន្លែងសំណាក់ ។ ហើយក្នុងរឿង



នេះទៀត អាប្រាជ្ញក៏បានពន្យល់ថាគ្មានសេចក្តីសម្រេចចិត្តយ៉ាងនេះឡើយ ។ អាប្រាជ្ញខំពន្យល់ថា ជ្រូកដែលជាអ្នកមានប្រាជ្ញាត្រូវតែមានកន្លែងសំរាកស្ងាត់ ហើយវាជាការសមរម្យណាស់ ដែលមេដឹកនាំ (អាប្រាជ្ញចាប់ផ្តើមហៅអាឈ្មុះថាជារៀមច្បងបដិវត្ត ឬមេដឹកនាំ) បានផ្ទះនេះនៅ ព្រោះថាឱ្យនៅក្នុងក្រោលដ៏ក្រខ្វក់នោះ មិនមែនជាការគាប់ប្រសើរឡើយ ។

សត្វទាំងឡាយកាន់តែស្រងាកចិត្តគ្រប់គ្នា កាលបើបានដឹងថាពួកជ្រូកមិនត្រឹមតែស៊ីបាយនៅផ្ទះបាយ ហើយប្រឡែងគ្នាលេងក្នុងបន្ទប់ទទួលភ្ញៀវប៉ុណ្ណោះទេ តែថែមទាំងដេកលើគ្រែទៀត ។ អាព្រួញធ្វើជាឥតដឹងឥតឮ ព្រោះវាជឿថា "អាឈ្មុះធ្វើត្រូវទាំងអស់" ។ ចំណែកមីកណ្តុបសេះ ហាក់ដូចជានៅចាំបានថា មានមាត្រាមួយនៃធម្មនុញ្ញ ដែលហាមមិនឱ្យសត្វដេកលើគ្រែទេ ។ វាដើរទៅឈរមុខជញ្ជាំងជង្រុក ហើយខំប្រកបអក្សរធម្មនុញ្ញ ដែលមានមាត្រា៧ ចារទុកនៅលើនោះ ។ ដល់ដឹងថាវាមើលមិនដាច់មាត្រាណាមួយហើយ វាក៏ដើររកមីភ្លុកឱ្យជួយ ។ វាសួរទៅមីភ្លុកថា៖ "មីភ្លុក អ្នែងមើលឱ្យអញត្រង់មាត្រាទី៤ តើវាមានដាក់ថាមិនឱ្យសត្វយើងដេកលើគ្រែមែនទេ?"

មីភ្លុកខំសម្លឹងជញ្ជាំង ប្រកបអក្សរដោយលំបាក ហើយមើលប្រាប់ថា : "មាត្រា ៤ ចែងថា គ្មានសត្វណាត្រូវដេកលើគ្រែដែលមានកំរាលទេ" ការដែលគួរឱ្យសរសើរគឺមីកណ្ដូបសេះបានប្រកែកថាមាត្រា៤ ដូចជាមិនដែលឮនិយាយពីកម្រាល ។ ក៏ប៉ុន្តែបើមីភ្លុកឃើញសរសេរដូច្នោះ លើជញ្ជាំងទៅហើយ ប្រហែលជាត្រូវហើយមើលទៅ ។ ពេលនោះអាប្រាជ្ញ ដើរមកដល់ ដោយមានឆ្កែពីរ បី មកតាមជាមួយផង ។ វាធ្វើអត្ថាធិប្បាយយ៉ាងក្បោះក្បាយដូចតទៅ :

"ឯងបានដឹងឮអស់ហើយសម្លាញ់ ថាពួកជ្រូកចូលទៅដេកក្នុងផ្ទះ ។ តើវាខុសអី ? ឯងនៅចាំថាមានមាត្រាមួយនៃធម្មនុញ្ញហាមមិនឱ្យសត្វដេកលើគ្រែ ។ ត្រូវហើយ តែអ្នកត្រូវដឹងថាគ្រែជាកន្លែងសំរាប់ដេក ។ គំនរចំបើងគឺជាគ្រែ ។ យើងជាពពួកជ្រូកបានយកកំរាលចេញអស់គ្រាន់តែទុកភួយមួយប៉ុណ្ណឹងសម្រាប់ដណ្ដប់ឱ្យកក់ក្ដៅ ។ ប៉ុន្តែក៏វានៅមិនទាន់សមល្មមនឹងកម្លាំងប្រាជ្ញា ដែលយើងខំធ្វើការបំពេញដូចសព្វថ្ងៃនេះទេ ។ តើអ្នកចង់ឱ្យអញដេកមិនស្កប់ឬអី ? តើអ្នកចង់ឱ្យអញគ្មានកម្លាំងធ្វើការឬ? អញជឿជាក់ថាអ្នកទាំងអស់មិនចង់ឱ្យអាស្មិតត្រឡប់មកវិញទេ" ។

សត្វទាំងអស់ស្រែកព្រមគ្នាថាវាមិនចង់ឱ្យពូស្មិតត្រឡប់



មកវិញទេ ម្ល៉ោះហើយរឿងដែលជ្រូកដេកលើគ្រែក៏ត្រូវចប់តែត្រឹមណោះ ។ ហើយឥឡូវនេះទៀត កាលបើបានដំណឹងថាជ្រូកគេអាចក្រោកពីដេកក្រោយសត្វដទៃទៀត មួយម៉ោងរាល់ៗព្រឹក វាទាំងអស់គ្នានៅស្ងៀមឥតមានប្រកែកអ្វីឡើយ ។

រហូតដល់ចុងឆ្នាំ សត្វទាំងអស់បានធ្វើការច្រើន តែវាទាំងអស់គ្នាក៏បានសប្បាយដែរ ។ ឆ្នាំនេះជាឆ្នាំពិបាក ។ ចំបើងនិងពោតបានលក់ចេញខ្លះ ចំណីដាក់ក្នុងជង្រុកសម្រាប់ឆ្នាំក្រោយមិនបានពេញដូចសព្វដងទេ ។ តែវាសង្ឃឹមថារហាត់ខ្យល់នឹងបន្ថែមអ្វីៗដែលខ្វះ ។ រហាត់ខ្យល់ត្រូវសង់បានពាក់កណ្ដាលហើយ ។ ក្រោយពីការច្រូតកាត់ សត្វក៏ត្រូវគេបង្ខំឱ្យធ្វើការកណ្ដាលថ្ងៃក្ដៅ អូសនិងដឹកដុំថ្មដើម្បីធ្វើឱ្យជញ្ជាំងរហាត់ខ្យល់បានខ្ពស់បន្តិច ។ អាប្រាជ្ញចេញមកធ្វើការទាំងយប់ក្រោមពន្លឺព្រះច័ន្ទដោយឥតមាននរណាបង្ខំចំនួនមួយ ឬពីរម៉ោងក្នុងមួយយប់ ។ ពេលសំរាកម្ដងៗ គេឃើញសត្វទាំងឡាយដើរជុំវិញរហាត់ខ្យល់ដែលសង់ទើបនឹងរួចពាក់កណ្ដាលនោះដើម្បីពិនិត្យនិងស្ទង់ជញ្ជាំងខ្លាចមានវៀចនិងខុសស្គងកន្លែងណាៗ ។ វាមិននឹកស្មានថាវាអាចសង់បានរបស់មួយដែលគួរឱ្យស្ញប់ស្ញែង យ៉ាងនេះ

សោះ ។ មានតែអាតើរទេ ដែលមិនសូវយើផ្លាបនឹងរហាត់ខ្យល់នេះ ។ ហើយដូចសព្វមួយដង វាតែងប្រាប់គេឯងថា មានតែសត្វលាទេ ដែលមានអាយុវែង ម្ល៉ោះហើយវាអាចដឹងហេតុការណ៍អ្វីៗទាំងអស់ទៅថ្ងៃមុខ ។

ខែវិច្ឆិកាមកដល់ ខ្យល់ជំនោរបក់ៗ កិច្ចការទាំងឡាយត្រូវផ្អាក ព្រោះភ្លៀងច្រើនពេក លាយស៊ីម៉ង់មិនកើត ។ យប់មួយភ្លៀងធ្លាក់យ៉ាងខ្លាំងព្រមទាំងមានព្យុះផង បណ្ដាលឲ្យគ្រឹះ និងជញ្ជាំងរហាត់ខ្យល់បាក់រលំ និងបណ្ដាលឲ្យក្បឿងនៃជង្រុករបើកអស់ជាច្រើន ។ មាន់ភ្ញាក់ពីដេកដោយភិតភ័យ ដូចជាស្រមៃឮគេបាញ់គ្នានៅជិតបង្កើយ ។

ព្រឹកឡើងសត្វទាំងអស់ចេញមកក្រៅ ហើយឃើញដងទង់ និងដើមឈើមួយដើមក្នុងចំការរលំ ។ វាឈរមើលការខូចខាតនេះ ព្រមទាំងស្រែកទ្រហោលាន់រំពងដោយសេចក្ដីអស់សង្ឃឹម ។ ការខូចខាតច្រើនបានកើតឡើងពីយប់មិញ ។ រហាត់ខ្យល់ត្រូវបាក់បែកអស់ ។ វារត់ព្រមគ្នាតំរង់ទៅកន្លែងនោះ ។ អាឈ្មុះដែលមិនសូវចេញមកក្រៅសោះនោះ បានរត់ទៅមុនគេមុនឯង ។ នៅពីមុខ វាបានឃើញកម្លាំងដែលវាខំសន្សំ ត្រូវវិនាសអស់រលីង ។ ជញ្ជាំងរហាត់បាក់ដួលរាបដល់ដី ថ្មខ្ទាត់ខ្ទាយពាសពេញ ។ វាទាំងអស់គ្នាឈរ



មើលជុំថ្មរាត់រាយជុំវិញខ្លួនវា — ដោយពុំចេញស្ដីអ្វីមួយម៉ាត់សោះ ។ អាឈ្មុះដើរចុះដើរឡើងឥតចេញស្ដី យូរៗកណ្ដាស់ផាត់លើដីដោយក្ដីអស់សង្ឃឹម ។ កន្ទុយវាបះឡើងត្រង់ ត្រីត្រវាត់ចុះឡើងដូចជាកំពុងគិតអ្វីមួយយ៉ាងពិបាក ។ ជួនកាលវាឈប់ធ្មឹងស្ងៀម ហាក់ដូចជានឹកឃើញអ្វីមួយ ។

“សម្លាប់” -- វាបញ្ចេញសម្លេងយ៉ាងស្រងូតស្រងាត់ “តើឯងដឹងទេថា អ្នកណាទទួលខុសត្រូវចំពោះរឿងនេះ? តើមាននរណាដឹងទេថាមានខ្មាំងចូលមកក្នុងពេលយប់ ហើយបំផ្លាញកំទេចរហាត់ខ្យល់យើង ? ខ្មាំងនោះគឺអាសំឡី ! ប្រាកដជាអាសំឡី ។ វាបញ្ចេញឈ្មោះនេះដោយអាការក្ដៅក្រហាយ ។ “ដោយការសងសឹកយ៉ាងកំសាក ក្រោយពីយើងបានបណ្ដេញវាចេញ អាក្បត់នេះ បានលួចចូលមកកន្លែងនេះនៅពេលយប់ ដើម្បីបំផ្លេចបំផ្លាញផែនការរបស់យើង ដែលបានខំកសាងជិតមួយឆ្នាំមកហើយ ។ សម្លាប់! អញនឹងប្រកាសកាត់ទោសប្រហារជីវិតអាសំឡី ។ អ្នកណាអាចសម្លាប់វាបាន នឹងបានទទួលឥស្សរិយយស និងបានទទួលរង្វាន់ផ្លែឈើកន្លះកញ្ជើ ។ បើអ្នកណាអាចចាប់វាបានទាំងរស់ អ្នកនោះនឹងបានទទួលរង្វាន់ផ្លែឈើមួយកញ្ជើ” ។

សត្វទាំងឡាយមានការងឿងឆ្ងល់ហួសចិត្ត ក្រោយពី

បានឮអាឈ្មុះផ្តន្ទាទោស និងដាក់កំហុសលើរូបអាសំឡី ។ មានការមិនពេញចិត្ត តែក៏មានសត្វខ្លះ កំពុងតែត្រិះរិះរកឧបាយកលដើម្បីចាប់ខ្លួនអាសំឡីដែរ ។ បន្តិចមកមានសត្វខ្លះរកឃើញស្នាមជើងជ្រូកមិនឆ្ងាយប៉ុន្មានពីទួល ។ តែដល់រត់តាមដាននេះតទៅទៀត ស្នាមនោះក៏បាត់ ។ អាឈ្មុះក៏គាន់តែជឿថាជាស្នាមជើងអាសំឡីដែលមកពីភូមិជិតខាង។

“កុំឱ្យខាតពេលសម្លាញ់” -- អាឈ្មុះស្រែកឡើងនៅពេលពិនិត្យស្នាមជើងជ្រូក -- “មានការច្រើនណាស់ដែលត្រូវធ្វើ ។ នៅព្រឹកនេះយើងនឹងសង់ជាថ្មី ។ យើងនឹងបន្តកិច្ចការយើងទៀត ថ្វីបើមានកំដៅថ្ងៃ ព្យុះ ឬភ្លៀងយ៉ាងណាក៏ដោយ ។ យើងនឹងប្រដៅអាក្បត់នេះឱ្យវាដឹងខ្លួនថាវាមិនអាចនឹងមកបំផ្លាញកិច្ចការរបស់យើងបានដោយងាយយ៉ាងនេះតទៅទៀតបានឡើយ ។ ចូរចាំឱ្យច្បាស់ សម្លាញ់ ! ថាគ្មានអ្វីដែលអាចមកកែប្រែផែនការរបស់យើងបានជាដាច់ខាត ។ យើងត្រូវតែធ្វើដំណើរទៅមុខទៀត ទៅមុខទៀត សម្លាញ់ ! ជយោ រហាត់ខ្យល់ ជយោ សត្វទាំងឡាយនៅភូមិសម្រែង !”



## ចំពូក ៧

ឆ្នាំនេះប្លែកខុសសព្វឆ្នាំ ។ ព្យុះភ្លៀងធ្លាក់ជោកជាំជាច្រើនខែ ។ សត្វទាំងឡាយ នៅតែបន្តកិច្ចការតទៅទៀតក្នុងការកសាងជាថ្មីឡើងវិញនូវរហាត់ខ្យល់ ។ វាដឹងថានរណាក៏ចាំមើលវាដែរ ។ មនុស្សនៅភូមិជិតខាងមុខជានឹងសើចចំអកឱ្យវា បើគេដឹងថា គំរោងរហាត់ខ្យល់នេះនឹងពុំបានសំរេចដូចបំណង ។

គ្មាននរណាជឿសោះថាអាសំឡីជាអ្នកបំផ្លាញរហាត់ខ្យល់ ។ គេដឹងថា មកពីជញ្ជាំងវាស្តើងហើយមិនមាំបានជារហាត់នេះបាក់រលំបាន ។ ក៏ប៉ុន្តែសត្វខ្លះ នៅតែមិនព្រមជឿ ។ ម្តងនេះវារៀបជញ្ជាំងក្រាស់ប្រហែល ១ ម៉ែត គឺមាំជាងមុន ៣ ដង ។ ម្ល៉ោះហើយវាត្រូវការថ្មកាន់តែច្រើនជាងមុន ។ ប៉ុន្តែការបំបែកនិងជញ្ជូនថ្មត្រូវផ្អាកមួយពេលសិន ព្រោះធាតុអាកាសមិនហុចឱ្យ ។

កិច្ចការបានប្រព្រឹត្តទៅយ៉ាងពិបាកបំផុត ធ្វើឱ្យសត្វទាំងអស់ដូចជាអស់សង្ឃឹម ។

ភ្លៀងធ្លាក់កាន់តែច្រើន ចំណីក៏កាន់តែខ្វះខាត ។

សត្វទាំងអស់ខំធ្វើការទាំងរងា និងស្រេកឃ្លាន ។ មានតែអាព្រួញនិងមីកណ្តុបសេះទេដែលមិនទាន់អស់សង្ឃឹម ។ អាប្រាជ្ញខំដើរឃោសនាដើម្បីលើកទឹកចិត្តដោយរៀបរាប់ពីសុភមង្គលនិងសេចក្តីថ្លៃថ្នូរនៃការងារ ។ ក៏ប៉ុន្តែសត្វទាំងឡាយមិនបានយកចិត្តទុកដាក់នឹងពាក្យឃោសនារបស់អាប្រាជ្ញនេះទេ ។ វាទាំងអស់មានជំនឿលើសេចក្តីមានះរបស់អាព្រួញទៅវិញ ។ ស្បៀងកាន់តែខ្វះខាតខ្លាំងឡើង គ្រាប់ពោតកាន់តែខ្សត់ទៅ ។ ឥឡូវត្រូវយកមើមឈើមកជំនួស ។ ប៉ុន្តែ ការរកមើមឈើក៏កាន់តែពិបាកឡើងដែរ ព្រោះវាមិនងាយនឹងរកបាន ។ ប៉ុន្មានថ្ងៃមកហើយដែលសត្វទាំងឡាយបានចំណីមិនគ្រប់គ្រាន់ ។ ការអត់បាយប្រហែលជាជិតមកដល់ហើយ ។

អាឈ្មុះយល់ថា មិនត្រូវផ្សាយដំណឹងអាក្រក់នេះឱ្យសត្វទាំងឡាយដឹងឡើយ ។ ប៉ុន្តែមនុស្សបានយករឿងរហាត់នេះទៅនិយាយឃោសនាអាក្រក់ពីសត្វនៅភូមិសំរែង ។ ពតិមានបានផ្សាយពាសពេញថា សត្វនៅភូមិសំរែងកំពុងជួបប្រទះនូវការស្រេកឃ្លាននិងជម្ងឺ ហើយសព្វថ្ងៃសត្វទាំងអស់កំពុងតែប្រខាំហែកហួរ កាប់ចាក់សម្លាប់គ្នាឯង ។ អាឈ្មុះមានការបារម្ភខ្លាចតែវាលាក់សេចក្តីពិតមិនបាន ។ ដូច្នេះ



ហើយ បានជាវាបានអង្វរពូពាង ដែលឧស្សាហ៍ចេញចូលភូមិសំរែង ឱ្យជួយធ្វើការឃោសនាប្រឆាំងនឹងពាក្យចចាមអារាមរបស់មនុស្ស ។

ដោយសត្វទាំងអស់ ក្រៅពីអាឈ្មុះ ពុំដែលបានធ្វើការទាក់ទងជាមួយពូពាង ទើបអាឈ្មុះហៅសត្វខ្លះ ជាពិសេសពពែឱ្យមកជួបពូពាង ដើម្បីពន្យល់ថា ចំណីនៅភូមិសំរែងឥតខ្វះដូចពាក្យគេថានោះទេ ។ អាឈ្មុះបញ្ជាឱ្យយកខ្សាច់ដាក់ក្នុងកញ្ជើជាងពាក់កណ្តាល ហើយបំពេញដោយស្រូវឬគ្រាប់ពោត ។ ម៉្លោះហើយក្នុងពេលដែលពូពាងចូលមកក្នុងភូមិម្តង ៗ អាឈ្មុះតែងតែបង្ហាញដល់គាត់នូវកញ្ជើដែលគាត់ឃើញពេញទៅដោយចំណី ។ ពូពាងក៏ចាប់ផ្សាយដំណឹងទៅក្រៅថា គ្មានការស្រេកឃ្លានអ្វីឡើយនៅភូមិសំរែង គឺមិនដូចពាក្យចចាមអារាមនោះទេ ។

បីបួនខែក្រោយមក ការខ្វះខាតមានកាន់តែខ្លាំងឡើង ស្បៀងត្រូវតែទិញមកពីក្រៅ ។ គេពុំសូវឃើញអាឈ្មុះទេក្នុងប៉ុន្មានថ្ងៃនេះ ។ វាលាក់ខ្លួនក្នុងផ្ទះធំ ដែលមានឆ្កែដ៏កំណាចចាំយាមនៅគ្រប់ទ្វារ ។ ពេលវាចេញមកក្រៅម្តង ៗ មានឆ្កែប្រាំមួយដើរអមវាហើយគ្រហឹមសំឡុតសត្វណាដែលហ៊ានដើរមកជិត ។ សូម្បីតែពេលប្រជុំម្តង ៗ ក៏វាកម្រនឹង

ចេញមកឱ្យគេឃើញដែរ ។ វាសុខចិត្តឱ្យបញ្ជាការអាប្រាជ្ញ ។

ព្រឹកមួយ ពេលប្រជុំ អាប្រាជ្ញបានប្រកាសថា ពួកមាន់ត្រូវប្រគល់ពងដែលវាពងបានទាំងប៉ុន្មានឱ្យអាឈ្មុះ ។ វាបានដឹងថា អាឈ្មុះបានសន្យាលក់ពងឱ្យពូពាងចំនួន ៤០០ពងក្នុងមួយអាទិត្យ ។ លុយដែលបានមកពីការលក់ពងនេះ នឹងទុកសំរាប់ទិញស្បៀង ដើម្បីឱ្យស្ថានការណ៍បានធូរស្រាលបន្តិច ។

លុះឮពាក្យបញ្ជានេះហើយ ពួកមាន់ស្រែកឡើងដោយសេចក្ដីក្ដៅក្រហាយ ។ វាយល់ច្បាស់ថា វាត្រូវតែធ្វើពលិកម្ម តែមិនជឿថា វាត្រូវផ្ដាក់ខ្លួនដល់ថ្នាក់នេះសោះ ។ វាទើបតែនឹងបានរៀបចំកន្លែងថ្មីសំរាប់ក្រាបពង ហើយដល់ឮថាគេនឹងប្រមូលពងទុកលក់ វាក្រោកឡើងគ្រប់គ្នាប្រឆាំងនឹងការលក់ពងនេះ ដែលវាចោទថាជាអំពើឧក្រិដ្ឋ ។

បដិវត្តន៍មួយទៀត ប្រហែលជានឹងមានកើតឡើងហើយ ក្រោមការដឹកនាំនៃមាន់ខ្មៅមួយ ។ មាន់ទាំងអស់ក៏ចាប់ផ្ដើមសកម្មភាពប្រឆាំងនឹងគំរោងការអាឈ្មុះ ។ វានាំគ្នាហើរទៅទំលើធ្នឹមជង្រុកហើយពងផ្ទុះមកដី ។ ដឹងភ្លាម អាឈ្មុះក៏បញ្ចេញផែនការតទល់ ។ វាបញ្ជាឱ្យបង្អត់ចំណី



មាន់ទាំងអស់ ហើយហាមដាច់ខាតផ្ដន្ទាទោសប្រហារជីវិតដល់សត្វណាដែលហ៊ានយកចំណីឱ្យមាន់ ។ ឆ្កែជាអ្នកទទួលបញ្ជានេះយកទៅអនុវត្ត ។ មាន់ធ្វើសកម្មភាពបានតែប្រាំថ្ងៃ រួចហើយក៏ចុះចាញ់នាំគ្នាត្រឡប់ទៅកាន់ទីកន្លែងដើមវិញ ។ មាន់ប្រាំបួនត្រូវបាត់បង់ជីវិតក្នុងពេលប្រឆាំង ។ អាឈ្មុះយកទៅកប់ចោលក្នុងចំការ ហើយប្រាប់គេឯងថា វាស្លាប់ដោយជម្ងឺ ។ ពូពាងធ្វើជាឥតដឹងឮរឿងទាំងអស់ ។ គាត់គិតតែពីរុញរទេះមកជញ្ជូនពងមាន់ពីភូមិក្នុងមួយអាទិត្យម្ដងជានិច្ច ។

រហូតមកដល់ពេលនេះ គេមិនដែលបានឃើញឬឮអ្វីពីអាសំឡីទេ ។ វាប្រហែលជាលាក់ខ្លួននៅកន្លែងណាមួយក្នុងភូមិជិតៗនេះ បើមិននៅភូមិទួលក្រាំងសៀម ក៏នៅភូមិត្រពាំងស្រកីដែរ ។ ឥឡូវអាឈ្មុះកាន់តែធ្វើការទាក់ទងជាមួយមនុស្សក្នុងភូមិជិតខាង ។ នៅគៀនជង្រុកគេឃើញមានគំនរឈើហ៊ុបដែលត្រូវទុកចោលជាច្រើនឆ្នាំមកហើយ ហើយដែលពូពាងចេះតែមកអង្វរសុំទិញពីអាឈ្មុះ ។ ក៏ប៉ុន្តែគេដឹងថា ពូថងនិងពូយៀងក៏ចង់បានឈើហ៊ុបនេះដែរ ។ អាឈ្មុះគិតយកឈើហ៊ុបនេះដូរយកអាសំឡីឱ្យតែដឹងថា វាពួននៅភូមិណា ។ តែនៅទីបំផុតវាធ្វើការមិនបានសំរេច ព្រោះពេលដែលវាជិតត្រូវរ៉ូវជាមួយពូយៀង គេដឹងថា អាសំឡី

រត់ទៅពួននៅភូមិពួថង ហើយដល់វាមកត្រូវរំផាយពួចាំង ពួង អាសំឡីរត់ទៅពួននៅភូមិពួយៀងវិញ ។

ថ្ងៃមួយ ស្រាប់តែមានការភ្ញើលឆោឡោឡើង ក្នុងភូមិសំរែង ព្រោះមានគេឃើញអាសំឡីលួចចូលមកក្នុងភូមិនៅពេលយប់ ។ សត្វទាំងអស់មានការព្រួយបារម្ភជាច្រើន ព្រោះអាសំឡីមកឆាឆៅយ៉ាងនេះ ធ្វើឱ្យដេកពួនមិនបាន ។

តាមពិត រាល់យប់អាសំឡី លួចចូលមកតាមច្រកងងិត ហើយធ្វើអំពើផ្ដេសផ្ដាសគ្រប់បែបយ៉ាង ។ វាលួចពោត ទាត់ធុងទឹកដោះគោឱ្យកំពប់ បំបែកពងមាន់ ជាន់បំផ្លាញរបងបន្លែ ខាំបំផ្លាញសំបកដើមឈើដែលកំពុងផ្លែ ។ ឥឡូវឱ្យតែមានអ្វីខូចខាតក្នុងភូមិ គេនឹងដាក់កំហុសមកលើអាសំឡី ។ បើមានបង្អួចណាបែកឬបាក់បែក ឬក៏មានទទឹកណាត្រូវស្អុះរន្ធ គេនាំគ្នាថាអាសំឡីបានមកបំផ្លាញពីយប់មិញ ។ បើគេរកសោជង្រុកមិនឃើញ គេថាអាសំឡីបានលួចយកទៅចោលក្នុងអណ្ដូង ។ សត្វទាំងអស់នៅតែជឿថាអាសំឡីលួចមកបំផ្លាញឬឆាឆៅរាល់យប់ ថ្វីបើជួនកាលគេរកឃើញសោជង្រុកដែលថាបាត់នោះនៅក្រោមគំនរចំបើងទៅវិញក៏ដោយ ។ មេគោក៏ជឿថា អាសំឡីលបចូលមកក្នុងក្រោល ហើយលួចរិតទឹកដោះវាពេលដែលវាកំពុងដេក ។ សូម្បីតែកណ្ដុរ មកឆាឆៅ



លួចចំណីស៊ីក្នុងជង្រុក ក៏គេជឿថាវាបានត្រូវជើងជាមួយអាសំឡីដែរ ។

អាឈ្មុះ បានបង្កើតគណៈកម្មការមួយសំរាប់ធ្វើការអង្កេតលើសកម្មភាពរបស់អាសំឡី ។ វាប្រើហ្វូងឆ្កែដែលជាសេនាធ្លាលំរបស់វាឱ្យដើរត្រួតជុំវិញភូមិ ដោយមានសត្វខ្លះដើរតាមក្រោយ ។ នៅស្ទើរគ្រប់កន្លែងអាឈ្មុះឈប់និងហិតក្លិន ដើម្បីរកមើលស្នាមជើងអាសំឡី ព្រោះវាអួតអាងថា វាអាចរកស្នាមជើងឃើញដោយយកច្រមុះហិតក្លិន ។ វាហិតរកក្លិនអាសំឡីគ្រប់ច្រកល្ហក ក្នុងជង្រុក ក្នុងក្រោល ក្នុងទ្រុងមាន់ ក្នុងសួនបន្លែ ។ នៅគ្រប់កន្លែង វាបានឃើញស្នាមជើងអាសំឡី ។ អាឈ្មុះដាក់ច្រមុះលើដីហិតបីបួនដង រួចហើយស្រែកយ៉ាងខ្លាំងដោយសេចក្ដីក្ដៅក្រហាយ ៖

"អាសំឡីប្រាកដជាចូលមកកន្លែងនេះ ព្រោះអញធុំក្លិនវា" ចាប់ពីពេលនោះមកពាក្យ "អាសំឡី" មួយម៉ាត់នេះធ្វើឱ្យឆ្កែទាំងអស់ក្ដៅក្រហាយ ស្រែកគ្រហឹមបញ្ចេញចង្កូមដ៏សាហាវ ។

សត្វទាំងអស់មានសេចក្ដីព្រួយបារម្ភ ថ្វីបើអាសំឡីពុំមានអានុភាពមកលើវាក្លាម ។ យ៉ាងណាក៏ដោយ តែវាបានធ្វើឱ្យសត្វទាំងអស់គិតភ័យដល់មហន្តរាយដែលនៅពីមុខវាជានិច្ច។

យប់នោះ អាប្រាជ្ញកេណ្ឌសត្វទាំងអស់ឱ្យចូលក្នុងជង្រុក ដើម្បីប្រាប់ដំណឹងពិសេសមួយ ។ ដោយទឹកមុខមិនស្រួល និងសម្លេងញ័រ ។ អាប្រាជ្ញស្រែកឡើងថា ៖

"សមមិត្ត !" មានរឿងដ៏ចម្លែកមួយបានកើតឡើង គឺអាសំឡីបានលក់ខ្លួនឱ្យអាយៀង ម្ចាស់ភូមិត្រពាំងស្រីហើយ ។ ឥឡូវ អាយៀង បំរុងនឹងមកវាយដណ្តើមភូមិសំវែងយកពីយើង ! អាសំឡីជាអ្នកបង្ហាញផ្លូវអាយៀង ។ យើងទាំងអស់គ្នាដឹងថា អាសំឡីធ្វើនេះដោយការសងសឹកនិងដោយការស្រេកឃ្លានល្មោភអំណាច ។ វាខុសហើយ ! សម្មាញ់ ! យើងដឹងទៀតថាអាសំឡីបានចូលដៃជាមួយអាស្វិតតាំងពីមុនមកម្ល៉េះ ! វាជាចារបុរសរបស់អាស្វិត ។ ក្នុងរឿងវាទាំងអស់នេះ យើងមានភស្តុតាងគ្រប់គ្រាន់ដោយឯកសារដែលយើងទើបតែរកឃើញ ។ ចំពោះអញ ឯកសារនេះវាគ្រប់គ្រាន់អាចធ្វើឱ្យយើងជឿបាន ។ តើឯងចាំបានទេ ថានៅពេលប្រតិបត្តិការសឹក "សម្រែងជ័យ" អាសំឡី បានផ្សៀតរកកលឧបាយធ្វើយ៉ាងណាឱ្យយើងចាញ់ ។ ក៏ប៉ុន្តែជាអកុសលវាពុំបានសម្រេច !" ។

សត្វទាំងអស់កាន់តែញាប់ញ័ររន្ធត់ ។ អាសំឡីដូចជាចិត្តអាក្រក់និង អយុត្តិធម៌ពេក បើសិនវាបានបំផ្លាញរហាត់ខ្យល់នេះមែន ។ សត្វទាំងអស់ពុំទាន់ជឿអាប្រាជ្ញភ្លាម ៗ ទេ ។ វាហាក់ដូចជានៅចាំបានថា ឬយ៉ាងហោចណាស់ក៏វាអាចស្មានបានស្រពេច ៗ ថា វាបានឃើញអាសំឡីរត់នាំមុខពួកសត្វទាំងអស់ក្នុងពេលប្រយុទ្ធជាមួយពួកស្វិត ។ វាបាននៅជាមួយសត្វទាំងអស់ជានិច្ច ក្នុងពេលមានអាសន្ននោះ ។ វាបានលើកទឹកចិត្ត វាបានរុលទៅមុខជានិច្ច ថ្វីបើខ្នងវាត្រូវគ្រាប់របស់ពួកស្វិតក៏ដោយ ។ រឿងទាំងអស់នេះធ្វើឱ្យសត្វទាំងអស់ពិបាកយល់ថា អាសំឡីចូលដៃជាមួយពួកស្វិតណាស់ ។ សូម្បីតែអាព្រួញដែលមិនសូវចេះនិយាយស្តីក៏ពិបាកនឹងយល់ដែរ ។ អាព្រួញដេកស្ងៀម ជើងមួយបត់ដាក់ក្រោមខ្លួនភ្នែកធ្មេចហើយខំប្រឹងគិត អំពីពាក្យឃោសនារបស់អាប្រាជ្ញ ។

"អញដូចជាមិនទាន់ជឿ" វាពោលឡើង « អាសំឡីបានតស៊ូយ៉ាងអង់អាចជាមួយយើង អញឃើញច្បាស់ណាស់ ។ យើងបានទាំងឱ្យឋានន្តរសក្តិវា ជាវីរៈបុរសថ្នាក់ទីមួយផងក្រោយពីការប្រយុទ្ធ "

"ខុសទេ សម្មាញ់ ! ព្រោះឥឡូវយើងបានរកឃើញរឿងពិតក្នុងឯកសារសម្ងាត់ដែលវាបានសរសេរទុកថាវាបានល្បួងយើងឱ្យធ្លាក់ក្នុងកណ្តាប់ដៃរបស់អាស្វិត"